សម្ព័ន្ធខ្មែរជំរឿន
និងការពារសិទ្ធិមនុស្ស
លីកាដូ

LICADHO

Cambodian League for the
Promotion and Defense of
Human Rights



# កុមារភាព នៅក្នុងពន្ធនាគារ៖

## ការចម្រើនវ័យនៅក្នុងពន្ធនាគារកម្ពុជា: រឿងរ៉ាវរបស់ ដារ៉ា

របាយការណ៍ចេញ
ខែកុម្ភៈ ឆ្នាំ២០១៥

# កុមារភាព នៅក្នុងពន្ធនាគារ៖

## ការចម្រើនវ័យនៅក្នុងពន្ធនាគារកម្ពុជា៖ រឿងរ៉ាវរបស់ ដារ៉ា

របាយការណ៍ចេញខែកុម្ភៈ ឆ្នាំ២០១៥

**សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ**

**LICADHO**

CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENSE OF HUMAN RIGHTS

# សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស (លីកាដូ)

លីកាដូ គឺជាអង្គការសិទ្ធិមនុស្សជាតិមួយនៅកម្ពុជា។ ចាប់តាំងពីអង្គការលីកាដូ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩២ អង្គការនេះ គឺជាអង្គការដែលស្ថិតនៅជួរមុខគេ ក្នុងកិច្ចការពារសិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច និងសិទ្ធិសង្គមរបស់ប្រជាពលរដ្ឋនៅក្នុងប្រទេសកម្ពុជា និងលើកកម្ពស់ការគោរពសិទ្ធិទាំងនោះ ពីរាជរដ្ឋាភិបាលកម្ពុជា និងអង្គការនានា។ ដោយបានកសាងនូវសមិទ្ធិផលល្អក្នុងអតីតកាល។ លីកាដូ បានបន្តដើរតួនាទីជាអ្នកតស៊ូមតិសម្រាប់ប្រជាពលរដ្ឋ និងធ្វើការឃ្លាំមើលរាជរដ្ឋាភិបាលតាមរយៈកម្មវិធីសិទ្ធិមនុស្សនានា ពីការិយាល័យកណ្តាលរបស់ខ្លួននៅភ្នំពេញ និងនៅ តាមសាខាទូទាំង ១៣ ខេត្ត-រាជធានីផ្សេងទៀត។

## កម្មវិធីឃ្លាំមើល និងការពារសិទ្ធិមនុស្ស

**ឃ្លាំមើលការរំលោភសិទ្ធិមនុស្ស ដែលប្រព្រឹត្តិ ដោយបុគ្គលអាជ្ញាធរ លើការរំលោភសិទ្ធិស្ត្រី និងការរំលោភសិទ្ធិកុមារៈ**

បុគ្គលិកលីកាដូ ធ្វើការស៊ើបអង្កេតលើករណីរំលោភសិទ្ធិមនុស្ស ដែលប្រព្រឹត្ត ដោយអាជ្ញាធរ ចំពោះការរំលោភបំពានលើស្ត្រី និងកុមារ ហើយជនរងគ្រោះ ត្រូវបានផ្តល់សេវាជួយជ្រោមជ្រែងតាមរយៈការធ្វើអន្តរាគមន៍ជាមួយអាជ្ញាធរមូលដ្ឋាន និងមន្ត្រីតុលាការ។

**ជំនួយផ្នែកវេជ្ជសាស្ត្រ និងសេវាកម្មសង្គមកិច្ចៈ**

ក្រុមគ្រូពេទ្យផ្តល់សេវាវេជ្ជសាស្ត្រដល់ជនជាប់ឃុំ និងមន្ត្រីពន្ធនាគារ ចំនួន១៤ កន្លែង ជនរងគ្រោះពីការរំលោភសិទ្ធិមនុស្ស និងគ្រួសារ ដែលស្ថិតនៅតំបន់តាំងទីលំនៅថ្មី។ ក្រុមការងារសេវាសង្គមធ្វើការវាយតម្លៃពីតម្រូវការរបស់ជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេ ហើយផ្តល់ជំនួយ សម្ភារៈ និងម្ហូបអាហាររយៈពេលខ្លី។

**ការឃ្លាំមើលពន្ធនាគារៈ**

អ្នកស្រាវជ្រាវពន្ធនាគារ ធ្វើការឃ្លាំមើលពន្ធនាគារចំនួន១៨ ដើម្បីធ្វើការវាយតម្លៃអំពីស្ថានភាពនៅក្នុងពន្ធនាគារ និងដើម្បីធានាថាជនជាប់ឃុំ ទទួលបាននូវតំណាងផ្នែកច្បាប់។

**ការប្រឹក្សាផ្នែកច្បាប់ និងកិច្ចការពារផ្នែកច្បាប់ៈ**

ជនរងគ្រោះ ត្រូវបានផ្តល់ជូននូវការប្រឹក្សាផ្នែកច្បាប់ ហើយចំពោះករណីសំខាន់ៗទទួលបាននូវកិច្ចការពារផ្នែកច្បាប់ ដែលផ្តល់ជូនដោយក្រុមប្រឹក្សាផ្នែកច្បាប់ និងក្រុមមេធាវីការពារសិទ្ធិមនុស្ស។

## កម្មវិធីលើកកម្ពស់ និងការទាក់ទាញមតិគាំទ្រ

**គាំទ្រសហជីព ក្រុមពលរដ្ឋមូលដ្ឋាន និងបណ្តាញនានាៈ**

ជួយដល់សហជីព ក្រុមពលរដ្ឋមូលដ្ឋាន និងសហគមន៍ ដែលរងគ្រោះ ដោយផ្តល់នូវកិច្ចការពារសេវាកម្មផ្នែកច្បាប់ ព្រមទាំងជួយពង្រឹងនូវសមត្ថភាពរបស់ពួកគេ ក្នុងការធ្វើយុទ្ធនាការ និងការតស៊ូមតិអំពីសិទ្ធិមនុស្ស។

**ការហ្វឹកហ្វឺនសហគមន៍ អប់រំ និងការតស៊ូមតិៈ**

អ្នកហ្វឹកហ្វឺន និងអ្នកទាក់ទាញមតិគាំទ្រ ធ្វើការអប់រំដល់ក្រុមគោលដៅជាក់លាក់មួយចំនួន បណ្តាញគាំទ្រកិច្ចការពារសិទ្ធិមនុស្សនៅថ្នាក់មូលដ្ឋាន និងធ្វើការតស៊ូមតិសម្រាប់ការផ្លាស់ប្តូរសង្គម និងច្បាប់ ជាមួយស្ត្រី យុវវ័យ និងកុមារ។

**ទាក់ទាញមតិគាំទ្រជាសាធារណៈ និងតាមសហគមន៍ៈ**

ករណីរំលោភសិទ្ធិមនុស្ស ដែលស៊ើបអង្កេត ដោយអង្គការលីកាដូ ត្រូវបានចងក្រងទុកនៅក្នុងប្រព័ន្ធទិន្នន័យដើម្បីឲ្យមានភាពងាយស្រួលក្នុងការស្វែងរកព័ត៌មាន វិភាគ ផលិត ជារបាយការណ៍ជាប្រចាំ (ការបោះពុម្ពជារបាយការណ៍ និងរបាយការណ៍សោតទស្សន៍) និងសម្រាប់ធ្វើការតស៊ូមតិផ្សេងៗទៀត។


**សម្រាប់ពត៌មានបន្ថែម សូមទាក់ទងៈ**

លោកស្រីវេជ្ជបណ្ឌិត ពុង ឈីវកេក, ប្រធានអង្គការសិទ្ធិមនុស្ស លីកាដូ
ផ្ទះលេខ ១៦ ផ្លូវ៩៩ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខៈ (+៨៥៥)២៣ ៧២៧ ១០២/២១៦ ៦០២
ទូរសារៈ (+៨៥៥)២៣ ៧២៧ ១០២/២១៧ ៦២៦

អ៊ីមែលៈ contact@licadho-cambodia.org
គេហទំព័រៈ www.licadho-cambodia.org Facebook: www.facebook.com/licadho Twitter: www.twitter.com/licadho

# មាតិកា


សេចក្តីផ្តើម ទំព័រ១

សាវតារ ទំព័រ២

ការខ្វះខាតវិធានការណ៍ផ្សេងទៀត ៤

កុមារភាពក្នុងពន្ធនាគារ ទំព័រ៥

វិធីសាស្រ្តក្នុងការសិក្សា ៥

សាវតាររបស់គ្រួសារ ៦

សាច់រឿងរបស់ ដារ៉ា ៦

ជម្រើសផ្សេងទៀតមិនត្រូវបានយក ទៅពិចារណា ៨

ស្ថានភាពពន្ធនាគារតាខ្មៅ ទំព័រ៩

ស្លាកស្នាមនៃជីវិតក្នុងពន្ធនាគារ ទំព័រ១០

បញ្ហាទាក់ទងនឹងការនិយាយ ១០

ការលូតលាស់ក្នុងបឋមវ័យ ១០

ការសម្លឹងមើលទៅអនាគត ១១

សេចក្តីសន្និដ្ឋាន ទំព័រ១៣

អនុសាសន៍ ទំព័រ១៦




ម្តាយ និងកូនតូច នៅពន្ធនាគារ ខេត្តបាត់ដំបង ឆ្នាំ២០១៤

# សេចក្តីផ្តើម

ត្រឹមខែវិច្ឆិកា ឆ្នាំ២០១៤ មានកុមារចំនួន ៤០ នាក់ អាយុចន្លោះពី ១ ខែ រហូតដល់ជិត ៤ ឆ្នាំ កំពុងរស់នៅជាមួយម្តាយ[១] ក្នុងពន្ធនាគារកម្ពុជា ក្នុងចំណោមពន្ធនាគារដែលឃ្លាំមើលដោយអង្គការលីកាដូ។[២] ប្រមាណពាក់កណ្តាលក្នុងចំណោមអ្នកទាំងនោះ បានចាប់កំណើតនៅក្នុងពន្ធនាគារ ហើយមិនស្គាល់រស់ជាតិជីវិតខាងក្រៅរបងពន្ធនាគារនោះឡើយ។ បើទោះជាមានការសិក្សាលម្អិតតិចតួច ដែលវាយតម្លៃអំពីផលប៉ះពាល់រយៈពេលយូរ ចំពោះការលូតលាស់របស់កុមារ ដោយសារតែការរស់នៅក្នុងពន្ធនាគារក៏ដោយ ក៏ប្រាកដណាស់ថា ចំពោះកុមារមួយចំនួនដែលមានបឋមវ័យក្នុងពន្ធនាគារ អាចមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ចំពោះការលូតលាស់ផ្លូវកាយ និងផ្លូវចិត្តរបស់កុមារ ហើយជីវិតនៅក្នុងពន្ធនាគារនៅកម្ពុជាក៏ដូចគ្នានោះដែរ។

របាយការណ៍នេះ ជារបាយការណ៍លើកទី២ ក្នុងចំណោមប្រភេទរបាយការណ៍ដែលលើកឡើងនូវករណីសិក្សាដែលចេញផ្សាយដោយអង្គការលីកាដូ ដើម្បីខិតខំប្រឹងប្រែងបំពេញនូវភាពខ្វះចន្លោះក្នុងការយល់ដឹង អំពីកុមារដែលមានវ័យក្មេងរស់នៅក្នុងពន្ធនាគារកម្ពុជា។ របាយការណ៍ទី១ បានសរសេរយ៉ាងលម្អិត អំពីបទពិសោធន៍របស់កុមារាម្នាក់ ឈ្មោះ សុគន្ធ ដែលបានរស់នៅជាមួយម្តាយក្នុងមណ្ឌលអប់រំកែប្រែទី២ រហូតដល់ សុគន្ធ មានអាយុ ៦ ឆ្នាំ និង ១០ ខែ។[៣] របាយការណ៍នោះ បានធ្វើសេចក្តីសន្និដ្ឋានថា ចំពោះករណីរបស់សុគន្ធ ឱកាសវិជ្ជមានក្នុងការកសាងសម្ព័ន្ធភាពជាមួយម្តាយ អាចមានលើស បទពិសោធន៍អវិជ្ជមានមួយចំនួន ដោយសារការរស់នៅក្នុងពន្ធនាគារ ប៉ុន្តែក៏បានធ្វើសេចក្តីសន្និដ្ឋានផងដែរថា អាជ្ញាធរពន្ធនាគារគួរតែបាន បំពេញកិច្ចការច្រើនជាងនេះ ដើម្បីធានាឲ្យមាននូវវិធានការពិសេសនានាដែលមានរួចជាស្រេច ក្នុងការការពារកុមារពីផលប៉ះពាល់ដែលមានគ្រោះថ្នាក់ដទៃទៀត។

ករណីសិក្សាទី២នេះ រៀបរាប់អំពីសាច់រឿងដែលមានលក្ខណៈខុសពីករណីមុន។ ករណីសិក្សានេះ រៀបរាប់អំពីសាច់រឿងរបស់ ដារ៉ា[៤] ដែលបានរស់នៅជាមួយម្តាយ នៅក្នុងពន្ធនាគារតាខ្មៅ តាំងពីពេលចាប់កំណើត រហូតដល់ដារ៉ាមានអាយុជាង ៣ ឆ្នាំ កន្លះ។ ឪពុកម្តាយ និងស្ត្រីម្នាក់ដែលត្រូវ ដារ៉ា ស្គាល់ថាជា "យាយ" របស់ដារ៉ា កំពុងជាប់ឃុំឃាំងរយៈពេល ១៥ ឆ្នាំ ពីបទសម្លាប់ "ជីតា" របស់គេ។ ឥឡូវនេះ ដារ៉ា មានអាយុជាង ៥ ឆ្នាំហើយ ប៉ុន្តែ ដារ៉ាចេះនិយាយតែពីរ បីម៉ាត់ប៉ុណ្ណោះ។

ចំពោះរបាយការណ៍ទាំងនេះ អង្គការលីកាដូមានបំណងបង្កើតឲ្យមានការយល់ដឹង ឲ្យបានទូលំទូលាយជាងនេះ ជាពិសេសក្នុងចំណោមអាជ្ញាធរពន្ធនាគារ និងអាជ្ញាធរតុលាការកម្ពុជា ដើម្បីឲ្យ



ម្តាយ និងកូនស្រី នៅពន្ធនាគារ ខេត្តបន្ទាយមានជ័យ ឆ្នាំ២០១១

ដឹងថា តើពេលវេលាណាជាពេលវេលាសមស្រប និងសមហេតុផលក្នុងការអនុញ្ញាតឲ្យកុមារ រស់នៅជាមួយម្តាយក្នុងពន្ធនាគារ ហើយការផ្តល់ជូនជាពិសេស ដែលត្រូវតែមានរួចជាស្រេច ដើម្បីបំពេញនូវសេចក្តីត្រូវការជាចាំបាច់ទាំងរបស់ម្តាយ និងកូន។ ដោយផ្តោតទៅលើករណីសិក្សានីមួយៗ អង្គការលីកាដូ ក៏មានគោលបំណងផ្តល់នូវការរកឃើញមួយចំនួន អំពីអត្ថប្រយោជន៍នៃការរក្សាកុមារឲ្យនៅជិតម្តាយរបស់គេ ដែលក្នុងករណីខ្លះ មានលើសលប់ ទៅលើហានិភ័យដោយសារការរស់នៅក្នុងពន្ធនាគារ ដរាបណាពួកគេស្ថិតក្រោមអាយុ ៣ ឆ្នាំ ដូចមានចែងនៅក្នុងច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា។

ចាប់តាំងពីការបោះពុម្ពផ្សាយនូវរបាយការណ៍ អំពីសាច់រឿងរបស់ សុគន្ធ មក ជាការសោកស្តាយ ដោយឃើញថា មិនមានអនុសាសន៍ណាមួយរបស់អង្គការលីកាដូ ដែលបានដាក់ជូនចំពោះអាជ្ញាធរកម្ពុជា ត្រូវបានយកទៅអនុវត្តឲ្យបានត្រឹមត្រូវនោះទេ។ បើទោះជាមានការគួរឲ្យកោតសរសើរដែលថា មានកុមាររស់នៅក្នុងពន្ធនាគារ ជាមួយម្តាយមានចំនួនតិចជាងមុន បើប្រៀបធៀបនឹងឆ្នាំកន្លងទៅក៏ដោយ ក៏ប៉ុន្តែក៏នៅតែគួរឲ្យសោកស្តាយដែល អគ្គនាយកដ្ឋានពន្ធនាគារ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលជាស្ថាប័នគួរតែទទួលខុសត្រូវ ក្នុងការដឹកនាំការសិក្សា វាយតម្លៃ

[១] បច្ចុប្បន្ននេះ មិនមានកុមាររស់នៅក្នុងពន្ធនាគារកម្ពុជា ជាមួយឪពុក ឬ អាណាព្យាបាល ដ៏ទៃទៀតនោះទេ។
[២] ពន្ធនាគារ PJ មណ្ឌលអប់រំកែប្រែទី១ មណ្ឌលអប់រំកែប្រែទី២ មណ្ឌលអប់រំកែប្រែទី៣ មណ្ឌលអប់រំកែប្រែទី៤ ពន្ធនាគារតាខ្មៅ ពន្ធនាគារយោធាទួលស្លែង ពន្ធនាគារខេត្តព្រះសីហនុ ពន្ធនាគារខេត្តកំពង់ស្ពឺ ពន្ធនាគារខេត្តកំពត ពន្ធនាគារខេត្តកំពង់ឆ្នាំង ពន្ធនាគារខេត្តកំពង់ចាម ពន្ធនាគារខេត្តធំ ពន្ធនាគារខេត្តពោធិ៍សាត់ ពន្ធនាគារខេត្តបាត់ដំបង ពន្ធនាគារខេត្តបន្ទាយមានជ័យ ពន្ធនាគារខេត្តសៀមរាប ពន្ធនាគារខេត្តស្វាយរៀង ពន្ធនាគារខេត្តកោះកុង។
[៣] កុមារភាពនៅក្នុងពន្ធនាគារ៖ការចម្រើនវ័យនៅក្នុងពន្ធនាគារកម្ពុជា៖ រឿងរ៉ាវរបស់សុគន្ធ ខែតុលា ឆ្នាំ២០១៣ http://www.licadho-cambodia.org/reports.php?perm=182
[៤] មិនមែនជាឈ្មោះពិតប្រាកដរបស់គាត់ទេ។

ចំពោះការថែរក្សាកុមារដែលសមស្រប និងការដកហូត និងប្តូរទីកន្លែងរស់នៅរបស់កុមារចេញពីពន្ធនាគារដោយសុវត្ថិភាព[៩] ក៏នៅតែបន្តមិនទាន់ទទួលយកការទទួលខុសត្រូវ ទាក់ទងនឹងកុមារដែលកំពុងតែរស់នៅក្នុងពន្ធនាគារបច្ចុប្បន្ន។ នេះក៏ជារឿងដែលគួរឲ្យសោកស្តាយផងដែរ ដែលនារីមានផ្ទៃពោះ និងនារីដែលមានកូន នៅតែទទួលរងការឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ ដោយមិនចាំបាច់ និងទទួលរងទោសដាក់ពន្ធនាគារផងដែរ។

អង្គការលីកាដូ ជឿជាក់ថា បន្ទាប់ការចេញផ្សាយរបាយការណ៍ លើកទី២មួយនេះ អគ្គនាយកដ្ឋានពន្ធនាគារ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នឹងចាត់វិធានការណ៍ ដើម្បីឲ្យមានការយល់កាន់តែច្បាស់ជាងមុន និងដោះស្រាយបញ្ហា ទាក់ទងនឹងស្ថានភាពរបស់កុមារដែលរស់នៅក្នុងពន្ធនាគារ ជាមួយម្តាយ ដោយធានាថា ទាំងសិទ្ធិរបស់ម្តាយ និងកូនត្រូវបានគោរពឲ្យបានពេញលេញ។ ការចេញរបាយការណ៍ទាំងនេះមិនមែនមានន័យថា អង្គការលីកាដូ ទាមទារឲ្យទារកដែលទើបចាប់កំណើត និងកុមារតូចៗ ត្រូវតែដកហូតចេញពី ម្តាយដែលជាប់ក្នុងពន្ធនាគារនោះទេ ហើយអង្គការលីកាដូ ក៏មិនជឿជាក់ផងដែរថា ការអនុញ្ញាត ឲ្យកុមាររស់នៅជាមួយម្តាយក្នុងពន្ធនាគារ មិនមែនសុទ្ធតែជាដំណោះស្រាយដែលល្អបំផុត នោះដែរ។ ផ្ទុយមកវិញ អង្គការលីកាដូ ទាមទារឲ្យមានការសិក្សាវាយតម្លៃឲ្យបានពេញលេញ ច្បាស់លាស់ និងធ្វើឡើងជាបន្តបន្ទាប់ ចំពោះករណីនីមួយៗ ដើម្បី ធានាថា រាល់ការសម្រេចចិត្តត្រូវបានធ្វើឡើង ដោយគិតពីឧត្តមប្រយោជន៍របស់កុមារ។


កុមារីនៅក្នុងពន្ធនាគារ ខេត្តសៀមរាប ឆ្នាំ២០១៣

# សាវតារ

ចាប់តាំងពីការដាក់ឲ្យអនុវត្តច្បាប់ស្តីពីពន្ធនាគារ ខែធ្នូ ឆ្នាំ២០១១ ដែលបានកាត់បន្ថយកម្រិតអាយុរបស់កុមារ ដែលត្រូវអនុញ្ញាតឲ្យរស់នៅក្នុងពន្ធនាគារ ពី ៦ ឆ្នាំ មកត្រឹម ៣ ឆ្នាំមក ចំនួនកុមាររស់នៅក្នុងពន្ធនាគារកម្ពុជា បានថយចុះជាង ៥០ ភាគរយ។ ក្នុងខែបន្ទាប់ពីការ អនុម័តច្បាប់នេះ មានកុមារចំនួន ៧១ នាក់ រស់នៅក្នុងពន្ធនាគារ ហើយចំនួន ១៧ នាក់ អាយុលើសពី ៣ ឆ្នាំ ហើយ ៣ ឆ្នាំក្រោយមកមានកុមារត្រឹមតែ ៧ នាក់ប៉ុណ្ណោះដែលមានអាយុលើស ៣ ឆ្នាំ រស់នៅក្នុងពន្ធនាគារ។ អង្គការលីកាដូស្វាគមន៍ ចំពោះការកែប្រែច្បាប់កាលពីឆ្នាំ២០១១ ហើយ មានកម្លាំងចិត្តយ៉ាងខ្លាំង ដោយសារការកាត់បន្ថយចំនួនកុមាររស់នៅជាមួយម្តាយ ក្នុងពន្ធនាគារដ៏ច្រើន។ ទោះជាយ៉ាងណា តួលេខនេះ ភាគច្រើន ជាលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងជាបន្តបន្ទាប់របស់អង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការជាមួយកុមារ និងស្ត្រី នៅក្នុងពន្ធនាគារ រួមទាំងអង្គការលីកាដូផងដែរ ហើយគួរឲ្យសោកស្តាយ កិច្ចខិតខំប្រឹងប្រែងរបស់ភាគីអគ្គនាយកដ្ឋានពន្ធនាគារ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានលទ្ធផលតិចតួច។

លទ្ធផលមួយជាក់លាក់នៃវិសោធនកម្មច្បាប់គឺថា មានកុមារច្រើនជាងមុននៅកម្ពុជារស់នៅផ្សេងពីម្តាយដែលជាប់ពន្ធនាគារ (ម្តាយ ជាអាណាព្យាបាលសំខាន់បំផុតនៅក្នុងគ្រួសារភាគច្រើន)។

[៩] ច្បាប់ពន្ធនាគារកម្ពុជា មាត្រា៤១ ចែងថា កុមារដែលមានអាយុលើសពី ៣ ឆ្នាំ គួរតែជាបន្ទុករបស់ក្រសួងសង្គមកិច្ច អតីតយុវជន និងយុវនីតិសម្បទា ប្រសិនបើមិនមានអាណាព្យាបាលណា ទទួលយកកុមារទៅចិញ្ចឹមថែទាំនៅខាងក្រៅពន្ធនាគារ។

ក៏ប៉ុន្តែ ជាអកុសល មានការសិក្សាបែបស៊ីជម្រៅតិចតួចណាស់ ស្តីអំពី ឥទ្ធិពលនៃការជាប់ពន្ធនាគាររបស់ម្តាយ ដែលមានចំពោះកូន ឬក៏ តើមានអ្វីកើតឡើងនៅពេល ដែលកុមារត្រូវបានដកហូតចេញពីម្តាយ បន្ទាប់ពីអ្នកទាំងនោះធ្លាប់រស់នៅជាមួយម្តាយនៅក្នុងពន្ធនាគារ។ អង្គការលីកាដូ មិនទាន់បានដឹងអំពីកិច្ចខិតខំប្រឹងប្រែងណាមួយ នៅកម្ពុជា ក្នុងការកត់ត្រាចំនួនកុមារទូទៅ ដែលទទួលផលប៉ះពាល់ពីការជាប់ពន្ធនាគាររបស់ឪពុកម្តាយ ឬ អាណាព្យាបាលរបស់អ្នកទាំងនោះ នោះទេ។



ជញ្ជាំងរបងពន្ធនាគារ ខេត្តកំពត ឆ្នាំ២០១៣

ការសម្រេចអនុញ្ញាតឲ្យកុមារអាយុក្រោម ៣ ឆ្នាំ រស់នៅជាមួយម្តាយក្នុងពន្ធនាគារ គួរតែអាស្រ័យទៅលើការសិក្សាវាយតម្លៃឲ្យបានពេញលេញទៅស្ថានភាពករណីនីមួយៗ និង អាស្រ័យលើឧត្តមប្រយោជន៍របស់កុមារ។[៦] ការវាយតម្លៃ គួរតែធ្វើការពិចារណាទៅលើអាយុ ភេទ ភាពដឹងក្តី សុខភាព និងទំនាក់ទំនងជាមួយម្តាយ ហើយ និងការមានជម្រើសសមស្របដែលមាននៅខាងក្រៅ និងផលប៉ះពាល់ ដែលទំនងជាកើតមានចំពោះសុខភាព និងការលូតលាស់របស់កុមារ ដោយសារការរស់នៅក្នុងពន្ធនាគារ។ ការវាយតម្លៃស្រដៀងគ្នានេះគួរតែធ្វើឡើងផងដែរ ពេលដែលកុមារបានចាប់កំណើត ក្នុងពេលម្តាយជាប់ពន្ធនាគារ ដើម្បីសម្រេច ថាតើកុមារគួរតែស្នាក់នៅក្នុងពន្ធនាគាររយៈពេលប៉ុន្មាន ឬក៏ មិនគួរឲ្យស្នាក់នៅទាល់តែសោះតែម្តង។ តាមទស្សនៈរបស់អង្គការលីកាដូ ការសិក្សាវាយតម្លៃនេះត្រូវតែធ្វើឡើងជាបន្តបន្ទាប់ ដោយសារតែ ការប្រែប្រួលស្ថានភាពនៅក្នុងពន្ធនាគារ និងការប្រែប្រួលនៃសេចក្តីត្រូវការរបស់កុមារ។ នៅពេលដែលកុមារមានអាយុ ៣ ឆ្នាំ ការដាក់កុមារឲ្យរស់នៅដាច់ដោយឡែក ត្រូវតែធ្វើឡើង ដោយមានលក្ខណៈសមស្រប មានការជម្រាបឲ្យដឹងច្បាស់លាស់ និងមានការប្រុងប្រយ័ត្នបានត្រឹមត្រូវ ហើយការដាក់កុមារឲ្យនៅដាច់ដោយឡែកនេះ អាចធ្វើទៅបាន លុះត្រាតែមានការរៀបចំចាត់ចែងការថែទាំកុមារ នៅខាងក្រៅពន្ធនាគារ បានត្រឹមត្រូវ។

បើទោះជាសិក្សាវាយតម្លៃបែបនេះមានសារៈសំខាន់ក៏ដោយ ក៏នៅកម្ពុជា ហាក់ដូចជាមិនមានប្រព័ន្ធ និងគោលការណ៍ណែនាំច្បាស់លាស់ ដើម្បីកំណត់ថា ពេលណាជាពេលវេលាសមស្របសម្រាប់កុមាររស់នៅក្នុងពន្ធនាគារ ហើយថាតើត្រូវដកហូតកុមារចេញពីម្តាយរបស់អ្នកទាំងនោះ ដោយរបៀបណា ពេលដែលកុមារមានអាយុ ៣ ឆ្នាំ។ កុមារអាចត្រូវបានបញ្ជូនទៅពន្ធនាគារដែរ គ្រាន់តែដោយសារកុមារបានស្ថិតនៅជាមួយម្តាយ ក្នុងអំឡុងពេលចាប់ខ្លួន បើទោះ ជាមានជម្រើសរស់នៅខាងក្រៅពន្ធនាគារសមស្របក៏ដោយ ឬក៏កុមារប្រហែលជាស្នាក់នៅ ក្នុងពន្ធនាគារ ដោយសារការសម្រេចរបស់ម្តាយតែម្នាក់ឯង ដែលជារឿយៗ មិនបានពិចារណា អំពីឧត្តមប្រយោជន៍របស់កុមារ។ ក្នុងឆ្នាំ២០១៣ អង្គការលីកាដូបានទទួលព័ត៌មានថានៅក្នុងពន្ធនាគារមួយដែលពេលនោះមានកុមារច្រើននាក់អាយុលើស ៣ ឆ្នាំ រស់នៅទីនោះ ម្តាយរបស់កុមារត្រូវគេឲ្យពេលវេលាកំហិតត្រឹមតែ ១ សប្តាហ៍តែប៉ុណ្ណោះ ក្នុងការស្វែងរកកន្លែងរស់នៅផ្សេង សម្រាប់កូនៗរបស់អ្នកទាំងនោះ។ នាយកពន្ធនាគារដ៏ទៃទៀតក៏បានពន្យល់ប្រាប់អង្គការលីកាដូថា អាជ្ញាធរមិនមានសមត្ថភាពក្នុងការធានាថា ការដកហូតកុមារចេញពីម្តាយក្នុងពន្ធនាគារ ប្រព្រឹត្តទៅបានត្រឹមត្រូវនោះទេ ហើយថា ពួកគាត់មិនបានទទួលជំនួយអ្វីសោះពី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

ដើម្បីដោះស្រាយកង្វល់ទាំងអស់នេះ អង្គការមិនមែនរដ្ឋាភិបាល ជារឿយៗ នៅតែដើរតួនាទីផ្តួចផ្តើម ក្នុងការសិក្សាវាយតម្លៃលើករណីនីមួយៗ ដឹកនាំការពិភាក្សាជាមួយភាគីដែលពាក់ព័ន្ធ និងស្វែងរកកន្លែងថែទាំខាងក្រៅ ដែលសមស្របសម្រាប់កុមារ។ ចំពោះករណីជាច្រើន ពេលដែលអង្គការមិនមែនរដ្ឋាភិបាលមានការចូលរួម ឃើញថា មានជម្រើសផ្សេងទៀត សម្រាប់កុមារ ក្រៅពីរស់នៅក្នុងពន្ធនាគារ ដោយជាញឹកញាប់ គឺរស់នៅជាមួយសាច់ញាតិរបស់កុមារ។ បន្ថែមលើសពីនេះទៅទៀត ប្រសិនបើបានធ្វើការពិចារណា

[៦] វិធានក្រុងបាងកក មាត្រា ៤៩ និង ៥២ និងអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ មាត្រា ៣ (១)។

កុមារអាចត្រូវបានបញ្ជូនទៅពន្ធនាគារដែរ គ្រាន់តែ ដោយសារកុមារបានស្ថិតនៅជាមួយម្ដាយក្នុងអំឡុងពេលចាប់ខ្លួន បើទោះជាមានជម្រើសរស់នៅខាងក្រៅពន្ធនាគារសមស្របក៏ដោយ ឬក៏កុមារប្រហែលជាស្នាក់នៅ ក្នុងពន្ធនាគារ ដោយសារការសម្រេច របស់ម្ដាយតែម្នាក់ឯង ដែលជារឿយៗ មិនបានពិចារណា អំពីឧត្តមប្រយោជន៍របស់កុមារ។

ទៅលើជម្រើសទាំងនេះ តាំងពីដំបូង កុមារជាច្រើនប្រហែលជាជៀសផុតពីការរស់នៅក្នុងពន្ធនាគារ និងផលប៉ះពាល់ផ្សេងៗ ទាក់ទងនឹងសុខភាពផ្លូវកាយ និងផ្លូវចិត្ត។

## ការខ្វះខាតវិធានការណ៍ផ្សេងទៀត

គួរឲ្យសោកស្ដាយ ប្រព័ន្ធពន្ធនាគារកម្ពុជា មិនមានសមត្ថភាព ក្នុងការផ្គត់ផ្គង់សេចក្ដីត្រូវការជាមូលដ្ឋានភាគច្រើនរបស់កុមារ ដូចជា ការអប់រំ អាហារូបត្ថម្ភសមស្រប ការថែទាំសុខភាព និងការប្រាស្រ័យទាក់ទងក្នុងសង្គមនោះទេ។ កុមារដែលរស់ដាច់ដោយឡែកពីពិភពខាងក្រៅ ហើយទទួលការចិញ្ចឹមក្នុងស្ថានភាពមិនល្អជារឿយៗ ជួបប្រទះបញ្ហាធ្ងន់ធ្ងរ ទាក់ទងនឹងការលូតលាស់របស់កុមារ ហើយមានការលំបាកក្នុងការសម្របខ្លួន ចូលក្នុងសង្គមនៅពេលដែលអ្នកទាំងនោះចេញពីពន្ធនាគារ។ អង្គការលីកាដូ ក៏បានដឹងអំពីករណីដែលកុមារវ័យក្មេង ទទួលរងការវាយដំ នៅក្នុងពន្ធនាគារដោយមិនមានការអន្តរាគមន៍ ឬ វិធានការការពារពីសំណាក់អាជ្ញាធរផងដែរ។

បើទោះជាបែបនេះក៏ដោយ នៅកម្ពុជា ស្ត្រីមានផ្ទៃពោះ និងស្ត្រីមានកូន កម្រត្រូវបានគេលើកទោសមិនដាក់ក្នុងពន្ធនាគារ ដើម្បីទៅថែទាំក្រុមគ្រួសារ កាត់បន្ថយចំនួនកុមាររស់នៅក្នុងពន្ធនាគារ និងការពារពួកគេ ពីការទទួលរងឥទ្ធិពលគ្រោះថ្នាក់ដោយសាររស់នៅក្នុងពន្ធនាគារណាស់។ បញ្ហាបែបនេះ ក៏កើតមាន សូម្បីតែក្នុងករណីបទល្មើសតូចតាច ដែលមានជម្រើសផ្សេងៗជំនួសឲ្យការឃុំខ្លួនបណ្ដោះអាសន្នរង់ចាំសវនាការ និងការផ្ដន្ទាទោសមិនដាក់ពន្ធនាគារទំនងជាការឆ្លើយតបដ៏មានប្រសិទ្ធិភាព ជាងការដាក់ពន្ធនាគារ។ តាមពិត បើទោះជាចំនួនកុមាររស់នៅក្នុងពន្ធនាគារមាន ការថយចុះក៏ដោយ ក៏ប៉ុន្តែបច្ចុប្បន្ននេះ ស្ត្រីមានផ្ទៃពោះដែលរស់នៅក្នុងពន្ធនាគារមានចំនួនច្រើនជាង កាលពីបីឆ្នាំមុន។

ក្រមនីតិវិធីព្រហ្មទណ្ឌ របស់ព្រះរាជាណាចក្រកម្ពុជា បានចែងយ៉ាងច្បាស់ថា ជាគោលការណ៍ ជនត្រូវចោទត្រូវតែមានសេរីភាព ហើយការឃុំខ្លួនបណ្ដោះអាសន្នរង់ចាំ សវនាការ គួរតែធ្វើទៅតែជាមធ្យោបាយចុងក្រោយ ហើយចំពោះតែករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ឬ បទមជ្ឈិម ដែលមានច្បាប់កំណត់ផ្ដន្ទាទោសដាក់ពន្ធនាគារស្មើ ឬ លើសពីមួយឆ្នាំប៉ុណ្ណោះ។ ប៉ុន្តែ ក្នុងចំណោមស្ត្រី ៦១ នាក់ដែលមានផ្ទៃពោះ ឬក៏រស់នៅជាមួយកូនក្នុងពន្ធនាគារ ដែលឃ្លាំមើលដោយអង្គការលីកាដូ ក្នុងខែវិច្ឆិកា ឆ្នាំ២០១៤ នេះ មានស្ត្រីជាង ៥០ ភាគរយ ជាប់ឃុំខ្លួនបណ្ដោះអាសន្នរង់ចាំសវនាការ ដោយគ្រាន់តែត្រូវបានចោទប្រកាន់ពីបទល្មើសតូចតាចប៉ុណ្ណោះ បើប្រៀបធៀបនឹងអ្នកដទៃទៀត។ លើសពីនេះទៅទៀត ស្ត្រីមានផ្ទៃពោះ ១៨នាក់លើកលែងតែ២នាក់ ចេញ ត្រូវបានឃុំខ្លួនបណ្ដោះអាសន្នរង់ចាំសវនាការ។



កុមារានៅក្នុងពន្ធនាគារ ខេត្តសៀមរាប ឆ្នាំ២០១៣

# កុមារភាពក្នុងពន្ធនាគារ

## វិធីសាស្ត្រក្នុងការសិក្សា

ក្នុងខែកញ្ញា ឆ្នាំ២០១៣ គឺរយៈពេល៦ខែ បន្ទាប់ពី ដារ៉ា បានចាកចេញពីពន្ធនាគារតាខ្មៅ មជ្ឈមណ្ឌលអភិវឌ្ឍន៍កុមាររបស់អង្គការអ៊ីនឌីហ្គោ (Indigo)[៧] បានរៀបចំការសិក្សាវាយតម្លៃអំពីដំណើរការផ្លូវចិត្តរបស់គាត់ ដោយផ្តោតទៅលើឥទ្ធិពលនៃការរស់នៅក្នុងពន្ធនាគារ។ ដោយសារតែ ដារ៉ា មិនអាចនិយាយបាន ការសង្កេតនិង ការលេង ត្រូវបានប្រើប្រាស់ជាមធ្យោបាយក្នុង ការសិក្សាវាយតម្លៃពីការប្រព្រឹត្តិទៅរបស់គាត់។ ទំហំកំណត់ពីកម្រិត នៃជម្ងឺអសមត្ថភាពជំនាញទំនាក់ទំនងរបស់កុមារ (The Childhood Autism Rating Scale) ដោយប្រើប្រាស់ព័ត៌មាន ពីឪពុកម្តាយ និងការសង្កេតបែបវិជ្ជាជីវៈ ទៅលើអាកប្បកិរិយារបស់កុមារ ត្រូវបានប្រើប្រាស់ដើម្បីកំណត់ថា តើ ដារ៉ា ប្រហែលជាមានជម្ងឺអសមត្ថភាពជំនាញទំនាក់ទំនង ឬ យ៉ាងណា។

អង្គការអ៊ីនឌីហ្គោ (Indigo) បានរៀបចំការការសិក្សាវាយតម្លៃដារ៉ា ហើយបានធ្វើការសង្កេតទៅលើ ដារ៉ា ពេល ដារ៉ា បានជួបជុំនិងឃ្លាតចេញពីម្តាយ ឪពុក និង "យាយ" របស់គាត់ នៅពេលដែលដារ៉ាទៅសួរសុខទុក្ខអ្នកទាំងនោះនៅពន្ធនាគារតាខ្មៅ។ អង្គការ អ៊ីនឌីហ្គោ ក៏បានរៀបចំការសម្ភាសន៍ជាមួយយាយតាបង្កើតរបស់ ដារ៉ា និងបុគ្គលិកអង្គការលីកាដូ ដែលបានចុះ ទៅសួរសុខទុក្ខ ដារ៉ា និងគ្រួសាររបស់ ដារ៉ា ជាទៀងទាត់នៅក្នុងពន្ធនាគារផងដែរ។ ឪពុកម្តាយ ដារ៉ា "យាយ" និងតាបង្កើតរបស់ ដារ៉ា ក៏បានបំពេញកម្រងសំណួរអំពីចំណុចខ្លាំង និងការលំបាក (SDQ)[៨] អំពី ដារ៉ា ផងដែរ។

ចាប់តាំងពីខែសីហា ឆ្នាំ២០១៣ ដារ៉ា បានចូលរួមវគ្គព្យាបាលតាមបែបវេជ្ជសាស្ត្រ (Therapy) ជាទៀងទាត់ នៅឯមជ្ឈមណ្ឌលដើម្បីសុខភាពផ្លូវចិត្តរបស់កុមារ និងមនុស្សពេញវ័យ (Center for Child and Adolescent Mental Health) ដែលដំណើរការដោយអង្គការការីតាស កម្ពុជា[៩] ក្រោមការសហការជាមួយ ក្រសួងសុខាភិបាល នៅក្នុងមន្ទីរពេទ្យបង្អែកជ័យជំនះ ក្នុងទីក្រុងតាខ្មៅ។ ការសង្កេតទៅលើការព្យាបាល តាមបែបមិនមែនវេជ្ជសាស្ត្រជាបន្តបន្ទាប់ បានផ្តល់នូវប្រភពព័ត៌មានបន្ថែមទៀត សម្រាប់ករណីសិក្សានេះ។

ក្នុងរយៈពេល ១២ ខែ អង្គការលីកាដូ បានប្រមូលព័ត៌មានលម្អិតអំពីការរីកចម្រើន និង សុខុមាលភាពផ្លូវចិត្តរបស់ ដារ៉ា ជួបសម្ភាសន៍ជាមួយយាយតាបង្កើតរបស់ ដារ៉ា ដែល ដារ៉ា កំពុងរស់នៅ

[៧] http://www.Indigo-cambodia.com

[៨] កម្រងសំណួរអំពីចំណុចខ្លាំង និងការលំបាក (SDQ) ជាឧបករណ៍ពិនិត្យលើអាកប្បកិរិយា ជាពិសេសចំពោះកុមារ។ ឧបករណ៍នេះមានគោលបំណងផ្តល់នូវការវាយតម្លៃជំហានដំបូង អំពីសុខុមាលភាពផ្លូវចិត្តទូទៅ រួមទាំងស្ថានភាពអារម្មណ៍ ភាពសកម្មហួសហេតុ បញ្ហាក្នុងការ ប្រាស្រ័យទាក់ទងជាមួយកុមារដ៏ទៃទៀត និងកម្រិតនៃអាកប្បកិរិយាក្នុងការទំនាក់ទំនងក្នុងសង្គម។

[៩] http://www.caritascambodia.org/ccamh

ជាមួយ និងគ្រួសាររបស់ ដារ៉ា ដែលកំពុងស្ថិតនៅក្នុងពន្ធនាគារ រួមទាំងជនជាប់ឃុំដទៃទៀត មន្ត្រីពន្ធនាគារ និងអ្នកប្រឹក្សាផ្លូវចិត្ត។ អង្គការលីកាដូ ក៏បានជួបសម្ភាសន៍ជាមួយបុគ្គលិកអង្គការ ដែលបានជួយឲ្យ ដារ៉ា ផ្ទេរចេញពីពន្ធនាគារ និងបន្តតាមដានអំពីការរីកចម្រើនរបស់ដារ៉ា។ បុគ្គលិកអង្គការលីកាដូ ក៏បានសង្កេត ដារ៉ា អំឡុងពេលការព្យាបាលតាមបែបវេជ្ជសាស្ត្រ ទៅលើការនិយាយរបស់គាត់ នៅមជ្ឈមណ្ឌលដើម្បីសុខភាពផ្លូវចិត្តរបស់កុមារ និងមនុស្សពេញវ័យរបស់អង្គការការីតាស។ បុគ្គលិកអង្គការលីកាដូ ក៏បានពិនិត្យមើល ដារ៉ា ពេលដែល ដារ៉ា ជួបជាមួយសមាជិកគ្រួសាររបស់គាត់ដែលកំពុងជាប់នៅក្នុងពន្ធនាគារ និងការប្រាស្រ័យរបស់ ដារ៉ាជាមួយយាយតា និងជាមួយកុមារដទៃទៀត នៅឯកន្លែងរស់នៅថ្មីរបស់ ដារ៉ា នៅក្នុងខេត្តតាកែវ។

## សាវតាររបស់គ្រួសារ

ម្តាយរបស់ ដារ៉ា បានឆ្លងកាត់វ័យកុមារភាពដែលពោរពេញដោយការលំបាក និងរឿងគួរឲ្យតក់ស្លុត។ ក្នុងពេលជាទារក ឪពុកម្តាយបង្កើតរបស់ម្តាយដារ៉ា បានលក់គាត់ទៅឲ្យស្ត្រីម្នាក់ (ដែលម្តាយដារ៉ា ហៅថា "ម្តាយ")។ ម្តាយចិញ្ចឹមនោះ បានរៀបការចំនួន ៤ ដងរួចហើយ ហើយមានកូនខ្លួនឯងមួយចំនួនទៀត។ គ្រួសារម្តាយចិញ្ចឹមរបស់គាត់បានវាយដំគាត់ តាំងពីគាត់នៅកុមារភាពម្ល៉េះ ហើយពេលដែលគាត់មានអាយុ ១២ឆ្នាំ គាត់បានទទួលរងការរំលោភសេពសន្ថវៈ និងបៀតបៀនកេរ្តិ៍ខ្មាស់ ពីសំណាក់ស្វាមីទី៣ របស់ម្តាយចិញ្ចឹមរបស់គាត់ និងកូនប្រុសម្នាក់របស់ម្តាយចិញ្ចឹមគាត់។ ពេលគាត់មានអាយុ ១៣ ឆ្នាំ គាត់ត្រូវ បានគេលក់ទៅឲ្យកន្លែងប្រកបរបរផ្លូវភេទមួយ ហើយគាត់រកប្រាក់បាន ១០០ ដុល្លារក្នុងមួយខែពីការរកស៊ីផ្លូវភេទនេះ ប៉ុន្តែប្រាក់ ដែលគាត់រកបានទាំងអស់ ត្រូវធ្លាក់ទៅក្នុងហោប៉ៅរបស់ "ម្តាយ" ចិញ្ចឹមរបស់គាត់។ ម្តាយរបស់ ដារ៉ា ក្រោយមកចាប់ផ្តើមប្រើប្រាស់ថ្នាំញៀនគ្រប់ប្រភេទ ដែលអាចមាន ដូចជា ហេរ៉ូអ៊ីន អិលអេសឌី (LSD) និង ម៉ាទឹកកក។

ពេលគាត់មានអាយុ ២០ ឆ្នាំ គាត់បានជួបឪពុករបស់ ដារ៉ា ដែលពេលនោះ ឪពុក ដារ៉ា ធ្វើការជាអ្នកប្រមូលសំរាមក្នុងរាជធានីភ្នំពេញ។ ពួកគាត់ទាំងពីរបានរស់នៅជាមួយគ្នា ហើយម្តាយរបស់ ដារ៉ា បន្តប្រកបរបរផ្លូវភេទម្តងម្កាល ហើយរកចំណូលផ្សេងទៀត ពីការជួញដូរគ្រឿងញៀន។ មកដល់នាពេលនេះ ម្តាយរបស់ដារ៉ា បានកាត់បន្ថយការប្រើប្រាស់ថ្នាំញៀន ប៉ុន្តែ គាត់នៅតែបន្តពិសារគ្រឿងស្រវឹង និងបន្តប្រើប្រាស់ថ្នាំញៀនខ្លះៗ ពិសេស ម៉ាទឹកកក។ រយៈពេលបីបួនខែក្រោយមក ម្តាយរបស់ ដារ៉ា បានដឹងថា គាត់មានផ្ទៃពោះ ៣ ខែ រួចទៅហើយ។ បើទោះជា គាត់បានព្យាយាមកាត់បន្ថយការប្រើប្រាស់ថ្នាំញៀនក៏ដោយ ក៏គាត់នៅតែបន្តប្រើប្រាស់វា រហូតដល់ពេលចាប់ខ្លួន។

ក្នុងខែមីនា ឆ្នាំ២០០៩ ពេលដែលម្តាយដារ៉ាមានផ្ទៃពោះ ដារ៉ា ចំនួន ៥ ខែ គាត់ត្រូវបាន ចាប់ខ្លួន រួមជាមួយនឹងឪពុករបស់ ដារ៉ា និងម្តាយចិញ្ចឹមរបស់ម្តាយ ដារ៉ា ពីបទសម្លាប់ប្តីទី៣ របស់ម្តាយចិញ្ចឹមរបស់ម្តាយ ដារ៉ា។ ប្តីទី៣នេះ ជាបុគ្គលដែលបានប្រព្រឹត្តអំពើរំលោភសេពសន្ថវៈមកលើ ម្តាយដារ៉ា កាលពីគាត់មានអាយុ ១២ ឆ្នាំ។ ពេលដែលម្តាយដារ៉ា មកដល់ពន្ធនាគារដំបូង គាត់ត្រូវបានគេរាយការណ៍ប្រាប់ថា មានភាពហិង្សា និងមានភាពច្របូកច្របល់ ហើយមិននិយាយជាមួយនរណានោះទេ។ នេះប្រហែលជាដោយសារការផ្តាច់ថ្នាំញៀន និងដោយសារ ចរិកលក្ខណៈនៃបទល្មើសដែលគាត់ត្រូវបានចោទប្រកាន់។

ពេលដែល ដារ៉ា អាយុ ៧ ខែ ជនសង្ស័យទាំង ៣ នាក់ ត្រូវបានកាត់ទោស និង ផ្តន្ទាទោសដាក់ពន្ធនាគារចំនួន ១៥ឆ្នាំ។ ឪពុកនិងម្តាយរបស់ ដារ៉ា បានបដិសេធចំពោះការប្រព្រឹត្តអំពើនេះ ហើយបន្ទោសទៅលើម្តាយចិញ្ចឹមរបស់គាត់ និងស្វាមីទី៤ របស់ម្តាយចិញ្ចឹមគាត់។ ឪពុក ដារ៉ា បានប្តឹងទាស់ចំពោះសេចក្តីសម្រេចនេះ ប៉ុន្តែតុលាការនៅតែរក្សាសេចក្តីសម្រេចនេះដដែល។ រីឯម្តាយ ដារ៉ា វិញ មិនមានលទ្ធភាពក្នុងការប្តឹងទាស់ចំពោះសេចក្តីសម្រេចនេះ នោះទេ។

## សាច់រឿងរបស់ ដារ៉ា

ដារ៉ា បានចាប់កំណើតនៅខែកក្កដា ឆ្នាំ២០០៩ គឺរយៈពេល ៤ ខែ បន្ទាប់ពីឪពុកម្តាយ និងយាយរបស់ ដារ៉ា ត្រូវបានចាប់ខ្លួន។ ដារ៉ា បានចាប់កំណើតទាំងពិបាក ដោយមានជំនួយក្នុងការចាប់កំណើតផង។ បើទោះបីជា ដារ៉ា ជាទារកដែលទន់ខ្សោយ ហើយមានជម្ងឺរលាកសួត ក៏ ដារ៉ា និងម្តាយ ត្រូវបានបញ្ជូនត្រលប់ទៅពន្ធនាគារវិញ ត្រឹមតែរយៈពេល ៣ ថ្ងៃ បន្ទាប់ពីការ សម្រាលកូនហើយ។

ក្នុងពេល ដារ៉ា នៅជាទារក ដារ៉ា រស់ដោយសារការចិញ្ចឹមមិនទៀងទាត់ ដោយទឹកដោះម្តាយ និងទឹកដោះគោ។ ដោយសារតែបញ្ហាសុខភាពផ្លូវចិត្ត និងផ្លូវកាយរបស់ម្តាយ ដារ៉ា ពេលខ្លះ គាត់មិនអាចបំបៅដោះ ដារ៉ា រហូតដល់រយៈពេលមួយសប្តាហ៍ម្តង ហើយពេលដែល ដារ៉ា មាន អាយុ ១២ ខែ ម្តាយ ដារ៉ា ឈឺ ហើយគាត់មិនបានអាចបំបៅដោះ ដារ៉ា ដល់ទៅរយៈពេលមួយខែ។ ម្តាយដារ៉ាមិនបានទទួលជំនួយអ្វីសោះពីអាជ្ញាពន្ធនាគារ[10] ហើយគាត់មិនអាចមានលទ្ធភាពទិញទឹកដោះគោសម្រាប់ ដារ៉ា ឲ្យបានជាប់លាប់នោះទេ។ ពេលដារ៉ាចាប់ផ្តើមញ៉ាំអាហាររឹង ជាទូទៅ ដារ៉ាទទួលបានតែរបបអាហារធម្មតារបស់ពន្ធនាគារប៉ុណ្ណោះ គឺអាហារចំនួនពីរពេលក្នុងមួយថ្ងៃ ដែលមិនមានអាហារូបត្ថម្ភគ្រប់គ្រាន់នោះទេ។[11] មន្ត្រីពន្ធនាគារបានដឹងថា ដារ៉ា ឧស្សាហ៍ឃ្លាន ជាពិសេសពេលដែល ដារ៉ា នៅជាទារក។

នៅកម្ពុជា មានតែអ្នកជាប់ពន្ធនាគារក្រីក្រខ្លាំងប៉ុណ្ណោះ ដែលអាចរស់នៅដោយមានតែអាហារ និងទឹកផ្តល់ដោយពន្ធនាគារ។ ផ្ទុយទៅវិញ អ្នកអាចមានលទ្ធភាព បានទិញអាហារបន្ថែមដើម្បីបរិភោគ ហើយអ្នកដទៃទៀតពឹងផ្អែកលើអំណោយពីមិត្តភក្តិ និងបង

[10] អនុក្រឹតឆ្នាំ២០០៩ ស្តីពីរបបអាហារក្នុងពន្ធនាគារ ចែងថា ម្តាយដែលមិនអាចបំបៅដោះ កូនដែលមានអាយុក្រោម ១ ឆ្នាំ បាន គួរតែទទួលបាននូវទឹកដោះគោចំនួនពីរគីឡូក្រាម ក្នុងមួយខែ។

[11] ថវិកាប្រចាំថ្ងៃសម្រាប់អាហារ ដែលកំណត់ដោយអនុក្រឹតឆ្នាំ២០០៩ ស្តីពីរបបអាហារ ក្នុងពន្ធនាគារ គឺផ្តល់ ២៨០០ រៀល (០.៧០ ដុល្លារ) ចំពោះជនជាប់ឃុំម្នាក់ៗ ហើយម្តាយដែល មានកូននៅជាមួយ គួរទទួលបានរបបបន្ថែមទៀត ដែលមានតម្លៃស្មើនឹង ១៤០០ រៀល (០.៣៥ ដុល្លារ) សម្រាប់កុមារម្នាក់ ក្នុងមួយថ្ងៃ។ ជាធម្មតាពន្ធនាគារ មិនទទួលបានចំនួននេះពេញលេញ ដូចដែលមានចែងក្នុងអនុក្រឹតឆ្នាំ២០០៩ ស្តីពីរបបអាហារក្នុងពន្ធនាគារ នោះទេ ហើយប្រសិន បើពួកគេទទួលបានថវិកានេះ ក៏មិនប្រាកដថាថវិកាទាំងអស់នេះនឹងត្រូវចំណាយលើម្ហូប អាហារសម្រាប់ជនជាប់ឃុំនោះទេ។ របបថវិកាដែលបែងចែកឲ្យជនជាប់ឃុំ មិនទាន់ត្រូវបាន ពិនិត្យឡើងវិញអស់រយៈពេល ៥ ឆ្នាំ មកហើយ បើទោះជាមានការកើនឡើងតម្លៃម្ហូបអាហារ ក៏ដោយ។



ជនជាប់ឃុំជាបុរស និយាយជាមួយកុមារតូចម្នាក់ ឆ្នាំ២០១៣

ប្អូននានាដែលមកសួរសុខទុក្ខ។ សម្រាប់ ដារ៉ា និងម្ដាយ ដារ៉ា មានការជួយគាំទ្រផ្នែកសម្ភារៈ និងហិរញ្ញវត្ថុពីខាងក្រៅតិចតួចណាស់ នេះក៏ព្រោះសមាជិកគ្រួសារថ្មីរបស់គាត់ជាច្រើន ក៏នៅក្នុងពន្ធនាគារដែរ។ គ្រួសាររបស់ឪពុក ដារ៉ា ជួយគាំទ្របាននៅពេលដែលអ្នកទាំងនោះមានលទ្ធភាពប៉ុណ្ណោះ ហើយដោយអ្នកទាំងនោះរស់នៅនៅកន្លែងដែលមានត្រូវចំណាយពេល ៣ ម៉ោង ធ្វើដំណើរពីទីក្រុងតាខ្មៅផង ធ្វើឲ្យមានការលំបាកក្នុងការទៅសួរសុខទុក្ខជាទៀងទាត់។ ការជួយរបស់អង្គការមិនមែនរដ្ឋាភិបាល ក៏មានកម្រិតយ៉ាងខ្លាំង។

នៅក្នុងពន្ធនាគារ ដារ៉ា ត្រូវបានគេចាក់សោរជាមួយម្ដាយឲ្យនៅជាមួយមនុស្សយ៉ាងច្រើន នៅក្នុងបន្ទប់ដែលមានកំដៅក្ដៅខ្លាំងជាច្រើនម៉ោងក្នុងមួយថ្ងៃ ហើយពេលខ្លះ ត្រូវបានអ្នកជាប់ពន្ធនាគារជាស្ត្រី និងមន្ត្រីពន្ធនាគារផ្សេងទៀតធ្វើបាប។ ម្ដាយ ដារ៉ា ក៏បានសារភាពថាគាត់ តែងតែវាយ ដារ៉ា ហើយការរំលោភបំពាននេះមិនបានបញ្ឈប់នោះទេរហូតដល់ ដារ៉ា ចាកចេញពីពន្ធនាគារ។ ទោះបីជាឪពុក ដារ៉ា ក៏ត្រូវបានឃុំខ្លួននៅក្នុងពន្ធនាគារតាខ្មៅក៏ដោយ ក៏អាជ្ញាធរត្រឹមតែអនុញ្ញាតឲ្យគាត់ជួបកូនប្រុសរបស់គាត់ពីរ ឬ បីដង ប៉ុណ្ណោះក្នុងមួយឆ្នាំ។

អំពើរំលោភបំពានដែល ដារ៉ា បានទទួលរងដោយសារស្នាដៃរបស់ម្ដាយរបស់ខ្លួន គឺមានសភាពធ្ងន់ធ្ងរយ៉ាងខ្លាំង ពេលដែល ដារ៉ា ទើបមានអាយុបីបួនខែ។ ពេលខ្លះ គាត់ទះ ដារ៉ា ពេញមួយទំហឹងដែលធ្វើឲ្យ ដារ៉ា ដួលទៅលើកម្រាលឥដ្ឋ ហើយមានឈាមតាមច្រមុះ និងមាត់។ ស្លាកស្នាមដោយសារអំពើរំលោភបំពាន ដែលមាននៅលើរាងកាយរបស់ ដារ៉ា ពេលខ្លះ មើលឃើញច្បាស់តែម្ដង ប៉ុន្តែអាជ្ញាធរពន្ធនាគារមិនបានជួយអន្តរាគមន៍ទេ រហូតដល់ដារ៉ាមានអាយុមួយឆ្នាំ។ ពេលដែលអាជ្ញាធរពន្ធនាគារអន្តរាគមន៍ ការអន្តរាគមន៍របស់អាជ្ញាធរក៏មានលក្ខណៈមិនសមស្រប មិនផ្ដល់ផលចំណេញ ហើយគ្រោះថ្នាក់ថែមទៀតផង។ ពេលដែលម្ដាយ ដារ៉ា វាយដំ ដារ៉ា មន្ត្រីពន្ធនាគារ ត្រូវគេរាយការណ៍ថា បានវាយដំម្ដាយដារ៉ាតបវិញ ដែលកត្តានេះបន្តធ្វើឲ្យមានវដ្ត នៃអំពើហិង្សា។ បន្ទាប់ពីមានការអន្តរាគមន៍ក៏គ្រោះថ្នាក់នេះ ការវាយដំមានមិនញឹកញាប់ដូចមុននោះទេ ប៉ុន្តែនៅតែមានលក្ខណៈធ្ងន់ធ្ងរ ពេលកើតមានម្ដងៗ។ អង្គការលីកាដូព្រួយបារម្ភថា បន្ថែមពីលើអំពើរំលោភបំពានដែលកើតមានលើខ្លួនឯង ដារ៉ាប្រហែលបានឃើញនូវអំពើហិង្សាដែលកើតមានចំពោះម្ដាយរបស់ខ្លួនផងដែរ។

ដារ៉ា បានចេញពីពន្ធនាគារចំនួនត្រឹមតែពីរដងប៉ុណ្ណោះ អំឡុងពេលដែលគាត់រស់នៅទីនោះជាមួយម្ដាយរបស់គាត់ ហើយទាល់តែគាត់ឈឺធ្ងន់ធ្ងរ ទើបគាត់ត្រូវបញ្ជូនទៅមន្ទីរពេទ្យ។ ដារ៉ា ត្រូវបានបញ្ជូនទៅមន្ទីរពេទ្យលើកដំបូង ពេលដែលគាត់មានអាយុមួយឆ្នាំកន្លះ ហើយពេលនោះគាត់មានជម្ងឺរាគខ្លាំង។ លើកទី២ ដារ៉ា ត្រូវបានបញ្ជូនទៅមន្ទីរពេទ្យរយៈពេលបីថ្ងៃ ពេលដែលគាត់មានអាយុពីរឆ្នាំ បន្ទាប់ពីមានការប្រកាច់ ដោយសារជម្ងឺគ្រុនក្ដៅធ្ងន់ធ្ងរ ដែលមិនបានទទួលការព្យាបាលអស់រយៈពេល ១០ ថ្ងៃ កន្លងមកហើយ។ បើទោះបីជា ដារ៉ា មានបញ្ហាសុខភាពជាច្រើនក៏ដោយ អាជ្ញាធរពន្ធនាគារមិនបានថែរក្សាទុកដាក់ឯកសារពេទ្យរបស់ ដារ៉ា ហើយថែមទាំងមិនបានឃ្លាំមើល ឬ កត់ត្រាពីការលូតលាស់របស់ ដារ៉ា ផងដែរ។ តាមពិតទៅឯកសារពេទ្យរបស់ ដារ៉ា ដែលមានព័ត៌មានលម្អិត បានត្រឹមតែកត់ត្រាពីការលូតលាស់របស់ ដារ៉ា ពេលដែលដារ៉ាមានអាយុ ១ ឆ្នាំ ហើយ

ប្រវត្តិនៃការចាក់វ៉ាក់សាំងតែប៉ុណ្ណោះ។ បុគ្គលិកពេទ្យ ពន្ធនាគារបាន អះអាងថា ពួកគាត់បានកត់សម្គាល់នូវការនិយាយមិនកើតរបស់ ដារ៉ា ដំបូង ពេលដែល ដារ៉ា មានអាយុប្រហែល ២ ឆ្នាំ ប៉ុន្តែមិនមានវិធានការអ្វីត្រូវបានធ្វើឡើង ដើម្បីដោះស្រាយបញ្ហានេះទេ។ ក្រោយមក ដារ៉ា បានចាកចេញពីពន្ធនាគារ ដើម្បីទៅរស់នៅជាមួយយាយតាខាងឪពុកបង្កើតរបស់គេ ក្នុងខែមិនា ឆ្នាំ២០១៣ ហើយពេលនោះ ដារ៉ា មានអាយុ ៣ ឆ្នាំ និង ៨ ខែ។ មកត្រឹមពេលនោះ ដារ៉ា មិនទាន់អាចនិយាយបានមួយម៉ាត់នៅឡើយទេ។

## ជម្រើសផ្សេងទៀតមិនត្រូវបានយកទៅពិចារណា

នៅពេលដែល ដារ៉ា ចាប់កំណើត មិនមានការសិក្សាវាយតម្លៃណាមួយត្រូវបានធ្វើឡើង ដើម្បីកំណត់ថា តើវាជារឿងល្អ ឬអត់ចំពោះ ដារ៉ា ក្នុងការស្នាក់នៅជាមួយម្តាយក្នុងពន្ធនាគារ។ អាជ្ញាធរក៏មិនដែលបានទាក់ទងមកយាយតាបង្កើតរបស់ ដារ៉ា (អ្នកដែល ដារ៉ា កំពុងរស់នៅជាមួយនាពេលបច្ចុប្បន្ន) បើទោះជាអ្នកទាំងនោះបានប្រាប់តាំងពីដំបូងថា ពួកគាត់នឹងទទួល ដារ៉ា យកមកថែទាំបីបាច់។

អាជ្ញាធរក៏មិនបានចាត់វិធានការ នៅពេលដែលឃើញច្បាស់ថា ដារ៉ា ទទួលរងការរំលោភបំពានលើរាងកាយក៏ដោយ។ តាមពិតទៅបុគ្គលិករបស់អង្គការមិនមែនរដ្ឋាភិបាល ដែលបានដឹងអំពីការរំលោភបំពាននេះ បានព្យាយាមជម្រុញអាជ្ញាធរពន្ធនាគារ និងម្តាយ ដារ៉ា ឲ្យអនុញ្ញាតឲ្យ ដារ៉ា ទៅរស់នៅជាមួយសាច់ញាតិរបស់ ដារ៉ា ខាងក្រៅពន្ធនាគារ ប៉ុន្តែម្តាយដារ៉ាបដិសេធ ហើយអាជ្ញាធរក៏មិនជួយអន្តរាគមន៍ដែរ។

ទីបំផុត នៅពេលដែល ដារ៉ា ចាកចេញពីពន្ធនាគារនាខែមីនា ឆ្នាំ២០១៣ វាមិនមែនដោយ សារការពិចារណាទៅលើសុវត្ថិភាព និងសុខុមាលភាពរបស់ដារ៉ានោះទេ ប៉ុន្តែដោយសារតែ ដារ៉ា មានអាយុលើស ៣ ឆ្នាំ ហើយច្បាប់មិនអនុញ្ញាតឲ្យ ដារ៉ា បន្តស្នាក់នៅជាមួយម្តាយក្នុងពន្ធនាគារ តទៅទៀត។ ម្តាយដារ៉ាបានអនុញ្ញាតឲ្យ ដារ៉ា ចេញមករស់នៅខាងក្រៅដោយសង្ឃឹមថា ដារ៉ា នឹងអាច ទទួលបានការសិក្សារៀនសូត្រ បើទោះជាដារ៉ាមិនអាចនិយាយបាននៅឡើយ។

អាជ្ញាធរក៏មិនបានចាត់វិធានការ
នៅពេលដែលឃើញច្បាស់ថា ដារ៉ា
ទទួលរងការរំលោភបំពានលើ
រាងកាយក៏ដោយ។

បន្ទាប់ការសិក្សាវាយតម្លៃឯករាជ្យ ទៅលើស្ថានភាពគ្រួសារ ដែលធ្វើឡើងដោយអង្គការអន្តរជាតិមួយ ដោយមានការចូលរួមតិចតួចពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដារ៉ា ត្រូវបានបញ្ជូនឲ្យទៅរស់នៅខេត្តតាកែវ ជាមួយនិងយាយតាខាងឪពុករបស់ ដារ៉ា រួមនឹងជាមួយយាយទូត បងប្អូនជីដូនមួយពីរនាក់ដែលមានអាយុតិចជាងគាត់ និងប្អូនប្រុសរបស់ឪពុក ដារ៉ា ដែលមានអាយុទើបតែ ៤ ឆ្នាំ ក៏រស់នៅទីនោះដែរ។

បើទោះបីជាមានការសិក្សាវាយតម្លៃ អំពីស្ថានភាពគ្រួសារបានទូលំទូលាយក៏ដោយ ដំបូង ដារ៉ា នៅតែមិនទាន់មានសុវត្ថិភាពពីការរំលោភបំពាននៅឡើយទេ។ បន្ទាប់ពីគាត់ចាកចេញពីពន្ធនាគារ ហើយទៅរស់នៅទីនោះភ្លាម ដារ៉ា ទទួលរងការវាយដំពីសំណាក់ម្តាយមីងរបស់ ដារ៉ា ម្នាក់ ដែលរស់នៅទីនោះដែរ។ សំណាងល្អ បន្ទាប់ពីការស៊ើបអង្កេត និងការអន្តរាគមន៍ពីសំណាក់អង្គការ មិនមែនរដ្ឋាភិបាល ដែលបានជួយបញ្ជូន ដារ៉ា ឲ្យទៅរស់នៅទីនោះ ម្តាយមីងរូបនេះបានចាកចេញទៅរស់នៅកន្លែងផ្សេង ហើយគ្រួសារនោះបានទទួលការបណ្តុះបណ្តាលអំពីវិធាន ការដាក់ពិន័យដែលសមស្រប។ បើទោះជាម្តាយមីងរូបនោះ នៅតែមកលេងផ្ទះនោះជាញឹកញាប់ក៏ដោយ ប៉ុន្តែគាត់មិនបានសម្រាន្តនៅទីនោះទេ ហើយក៏មិនលឺមានការរាយការណ៍អំពីការរំលោភបំពានថ្មី ទៀតដែរ។



ខ្លោងទ្វារពន្ធនាគារតាខ្មៅ ស្ថិតក្នុងខេត្តកណ្ដាល ឆ្នាំ២០១៤

# ស្ថានភាពពន្ធនាគារតាខ្មៅ

ពន្ធនាគារតាខ្មៅ[១២] ជាពន្ធនាគារថ្មី បើប្រៀបធៀបជាមួយពន្ធនាគារដទៃទៀត ហើយស្ថិតនៅជាយរាជធានីភ្នំពេញ គឺកណ្ដាលទីក្រុងតាខ្មៅ។ ពន្ធនាគារនេះចាប់ផ្ដើមដំណើរក្នុងឆ្នាំ២០០៦ ដោយមានលទ្ធភាពផ្ទុកជនជាប់ឃុំសរុបចំនួន ៣១៤ នាក់ ហើយត្រូវបានចាត់ទុកជា "ពន្ធនាគារ គំរូ" របស់កម្ពុជា ដែលសាងសង់ឡើង ក្រោមជំនួយឧបត្ថម្ភផ្នែកហិរញ្ញវត្ថុពីរដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធីយុត្តិធម៌ព្រហ្មទណ្ឌនៅកម្ពុជា (CCJAP)។

បច្ចុប្បន្ននេះ ពន្ធនាគារតាខ្មៅជាពន្ធនាគារមួយក្នុង ចំណោមពន្ធនាគារដែលមានភាពចង្អៀតណែនជាងគេបំផុតនៅកម្ពុជា ហើយឥឡូវនេះ ពន្ធនាគារនេះកំពុងផ្ទុកជនជាប់ឃុំជិត ១០០០ នាក់ ដែលលើសលទ្ធភាពផ្ទុករបស់ខ្លួន ដល់ទៅជាង ៣ ដង។ ពេលដែល ដារ៉ា រស់នៅទីនេះ ពន្ធនាគារនេះ បានផ្ទុកជនជាប់ឃុំលើលទ្ធភាពផ្ទុករបស់ខ្លួន ចន្លោះពី ២១៤ ភាគរយ ដល់ ២៤៨ ភាគរយ។ ជនជាប់ឃុំជាបុរស និងនារី ត្រូវបានឃុំឃាំងនៅអគារ ដាច់ដោយឡែកពីគ្នា ហើយជនជាប់ឃុំជានារី ជាទូទៅ ត្រូវបានអនុញ្ញាតឲ្យចេញក្រៅបន្ទប់ ឃុំឃាំង ២ ឬ ៣ ម៉ោង ក្នុងមួយថ្ងៃ គឺទាំងពេលព្រឹក ទាំងល្ងាច។

ដូចគ្នាទៅនឹងពន្ធនាគារដទៃទៀតដែរ បន្ទប់ឃុំឃាំងនារីនៅក្នុងពន្ធនាគារតាខ្មៅ មិនមានភាពចង្អៀតណែន ដូចបន្ទប់ឃុំឃាំងបុរសនោះទេ។ ក្នុងពន្ធនាគារនេះ មានបន្ទប់ឃុំឃាំងនារី ចំនួនពីរផ្សេងគ្នា។ បន្ទប់ឃុំឃាំងធំមួយ ដាក់ជនជាប់ឃុំជានារីភាគច្រើន និងបន្ទប់តូចមួយទៀត ជាកន្លែងដែល ដារ៉ា បានរស់នៅជាមួយម្ដាយរបស់គាត់ ហើយមានផ្ទុកជនជាប់ឃុំជានារី ចន្លោះ ពី ៦ ទៅ ១០ នាក់។ បន្ទប់ទាំងពីរមានបន្ទប់ទឹក និងបង្គន់ធម្មតាមួយ។ ក្នុងអំឡុងពេលដែល ដារ៉ា រស់នៅទីនោះ ជាមធ្យម មានជនជាប់ឃុំជានារី ចំនួន ៣៧ នាក់ រស់នៅក្នុងបន្ទប់ឃុំឃាំង ទាំងពីរ។

ពន្ធនាគារតាខ្មៅ មិនមានកន្លែងថែទាំកុមារ និងកន្លែងលេងសម្រាប់កុមារនោះទេ។ តាមពិតទៅ មកដល់ត្រឹម ខែវិច្ឆិកា ឆ្នាំ២០១៤ ពន្ធនាគារកម្ពុជាត្រឹមតែបួនប៉ុណ្ណោះ ផ្ដល់ឲ្យកុមារ នូវឱកាសលេងកំសាន្ត និងការសិក្សាអប់រំជាមូលដ្ឋាននៅនឹងកន្លែង ហើយកម្មវិធីទាំងអស់គ្នា ត្រូវបានដំណើរការទៅដោយអង្គការមិនមែនរដ្ឋាភិបាល។ ក្នុងឆ្នាំ២០០៩ ពេលដែល ដារ៉ា ចាប់កំណើត មានអង្គការមិនមែនរដ្ឋាភិ បាលជាច្រើន ផ្ដល់ជំនួយដល់ជនជាប់ឃុំក្នុងពន្ធនាគារតាខ្មៅ ហើយ ផ្ដល់ឲ្យពួកគាត់នូវវគ្គបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈ និងបំណិនជីវិតជាច្រើន ការបណ្ដុះបណ្ដាលផ្នែកច្បាប់ និងការឧបត្ថម្ភអាហារសម្រាប់ជនជាប់ឃុំជាដើម។ នារីមានផ្ទៃពោះ និងកុមារ គួរតែត្រូវទទួលបានជំនួយឧបត្ថម្ភប្រចាំខែ មានដូចជា អាហារបន្ថែម និងសម្ភារៈអនាម័យ ប៉ុន្តែជំនួយឧបត្ថម្ភនេះ មិនមានជាទៀងទាត់ទេ ហើយក៏មិនអាចជឿជាក់បានដែរ។ អង្គការមិនមែនរដ្ឋាភិបាលមួយចំនួន ដែលបានធ្វើសកម្មភាពក្នុងពន្ធនាគារនេះ បានដកខ្លួនចេញដែលបណ្ដាល ឲ្យនារីមានផ្ទៃពោះ និងកុមារជាច្រើន មិនទទួលបានជំនួយឧបត្ថម្ភជាទៀងទាត់ពីខាងក្រៅនោះឡើយ។

[១២] ពន្ធនាគារតាខ្មៅ គឺត្រូវបានគេប្រើប្រាស់ជាទូទៅសម្គាល់ទៅលើឈ្មោះផ្លូវការគឺ ពន្ធនាគារខេត្តកណ្ដាល។



កុមារាមកសួរសុខទុក្ខម្តាយ នៅក្នុងមណ្ឌលអប់រំកែប្រែទី២ ឆ្នាំ២០១៣

# ស្លាកស្នាមនៃជីវិតក្នុងពន្ធនាគារ

## បញ្ហាទាក់ទងនឹងការនិយាយ

ពេលដែល ដារ៉ា ចាកចេញពីពន្ធនាគារក្នុង ខែមីនា ឆ្នាំ២០១៣ ការបញ្ចេញសម្លេងរបស់ ដារ៉ា បានតែបញ្ចេញសម្លេងថ្ងូរ និងត្អូញ ប៉ុណ្ណោះ ហើយបើទោះជាគាត់មានអាយុ ៥ ឆ្នាំ ហើយក៏ដោយ ក៏បញ្ហានេះមានភាពប្រសើងឡើងតិចតួចប៉ុណ្ណោះ។ ការលូតលាស់របស់គាត់មានភាពយឺត ហើយគាត់នៅតែមានភាពយឺតយ៉ាវយ៉ាងខ្លាំងក្នុងការធ្វើការទំនាក់ទំនងតាមរយៈពាក្យសម្តី។

ជម្ងឺអសមត្ថភាពជំនាញទំនាក់ទំនង មិនមែនជាហេតុផលនៃការពិបាកខ្លាំងក្នុងការនិយាយរបស់ ដារ៉ា នោះទេ។ ទំហំកំណត់ពីកម្រិតនៃជម្ងឺអសមត្ថភាព ជំនាញ ទំនាក់ទំនងរបស់កុមារ (The Childhood Autism Rating Scale) ដែលត្រូវបានប្រើប្រាស់ ក្នុងអំឡុងការសិក្សាវាយតម្លៃរបស់អង្គការ អ៊ីនឌីហ្គោ (Indigo) ដារ៉ា ស្ថិតក្នុងចំណាត់ថ្នាក់ ២៥ ក្នុងចន្លោះដែលមានពី ១៥ ទៅដល់ ៦០។ ហើយពិន្ទុអប្បបរមា ដែលអាចសន្និដ្ឋានថាមានរោគសញ្ញាជម្ងឺអសមត្ថភាពជំនាញទំនាក់ទំនង គឺ៣០។ ដូចនេះ ដារ៉ា មានជម្ងឺនេះទាបបំផុត។

បន្ទាប់ការព្យាបាលតាមបែបវេជ្ជសាស្រ្ត (Therapy) ទៅលើការនិយាយរបស់គាត់ ជាមួយអង្គការការីតាស អស់រយៈពេលមួយឆ្នាំមក ដារ៉ាអាចបញ្ចេញលម្លេងផ្សេងៗពីគ្នា ហើយ និយាយបានប្រហែលដប់ពាក្យ (ពាក្យមួយព្យាង្គៗ) ជាភាសាខ្មែរ ដូចជា យាយ រូច និងឆ្កែ។ អ្នកព្យាបាល ដារ៉ា តាមបែបវេជ្ជសាស្រ្ត (Therapist) បានបញ្ជាក់ថា ដារ៉ាបានបង្ហាញនូវ សមត្ថភាពផ្នែកផ្លូវចិត្ត ក្នុងការបន្តបង្កើនជំនាញទំនាក់ទំនងរបស់គាត់ និងជឿជាក់ថា តាមរយៈការព្យាបាលតាមបែបវេជ្ជសាស្រ្ត (Therapist) ជាបន្តបន្ទាប់ និងការជួយជ្រោមជ្រែងពីគ្រួសារ ដារ៉ា ប្រហែលអាចធ្វើការទំនាក់ទំនងបាន ដោយប្រើប្រាស់ពាក្យ និងឃ្លាសាមញ្ញៗ។

ជំនាញស្តាប់ភាសា (ការយល់) មានការលូតលាស់លឿនជាងការនិយាយរបស់គាត់ ប៉ុន្តែ នៅមានតែមានភាពយឺតយ៉ាវជាខ្លាំងប្រើប្រៀបធៀបជាមួយកុមារដ៏ទៃទៀត ដែលមានអាយុដូចគាត់។ ពេលដែលបុគ្គលិកអង្គការអ៊ីនឌីហ្គោ (Indigo) ជួប ដារ៉ា ដំបូងពេលគាត់អាយុ ៤ ឆ្នាំ បុគ្គលិកនោះបានធ្វើការសង្កេតលើ ដារ៉ា ដោយបានប្រាប់ ដារ៉ា តែម្តងថា "ជួយឲ្យពែងនោះមកខ្ញុំ" ដោយមាន ឬ មិនមានកាយវិការជំនួយ ហើយកម្រិតនេះជាកម្រិតយល់ដឹងទូទៅសម្រាប់កុមារ ដែលមានអាយុ ១ ឆ្នាំ ទៅ២ ឆ្នាំ។ ពេលគាត់អាយុ ៥ ឆ្នាំ បន្ទាប់ពីទទួលការព្យាបាលតាមបែបវេជ្ជសាស្រ្ត (Therapy) ជាបន្តបន្ទាប់មក ដារ៉ា អាចយល់កាបង្គាប់ចំនួនពីរឃ្លា ដូចជា "សូមទៅផ្ទះបាយ ហើយយកស្លាបព្រាមួយ" ដែលជាកម្រិតនៃការយល់ដឹង និងការលូតលាស់របស់កុមារមានអាយុចន្លោះពីរ ២ ទៅ ៣ ឆ្នាំ។ ឥឡូវ ដារ៉ា កាន់តែយល់ច្រើនថែមទៀត នូវអ្វី ដែលគេនិយាយទៅកាន់គាត់ ប៉ុន្តែគាត់មិនអាចឆ្លើយតបជាពាក្យសម្តីមកគេវិញបាន។ ការប្រើ កាយវិការរបស់គាត់ក៏មិនសូវស៊ីគ្នាទៅនឹងអាយុរបស់គាត់ ប៉ុន្តែអាចយល់បាន។ ដារ៉ាក៏បង្ហាញនូវការលំបាកយ៉ាងខ្លាំង ទាក់ទងនឹងកម្រិតនៃការប្រឹងប្រែងយកចិត្តទុកដាក់របស់គាត់។

## ការលូតលាស់ក្នុងបឋមវ័យ

លើកលែងតែរយៈពេល ២ ខែ ក្នុងឆ្នាំ២០១២ ចេញ គឺពេលដែលមានទារកអាយុ ៣ ខែ ស្នាក់នៅក្នុងបន្ទប់ជាមួយ ដារ៉ា មិនធ្លាប់

មានកុមារផ្សេងទៀតលេងជាមួយក្នុងពន្ធនាគារនោះទេ។ គាត់ក៏ខ្វះខាតសម្ភារៈសមស្របសម្រាប់លេង និងជំនួយប្រាជ្ញាស្មារតីផងដែរ។ គាត់ក៏មិនមាន ប្រដាប់ប្រដារលេង សៀវភៅ និងខ្មៅដៃដែរ ហើយគាត់នៅតែមិនទាន់អាចប្រើខ្មៅដៃបាន ត្រឹមត្រូវនៅឡើយ។ ក្នុងសិក្សាវាយតម្លៃដោយអង្គការអ៊ីនឌីហ្គោ (Indigo) ឃើញថា សមត្ថភាពទូទៅទាក់ទងនឹងចលនាទូទៅ (Gross Motor Skills) របស់គាត់មានភាពយឺតយ៉ាវយ៉ាងខ្លាំង ឧទាហរណ៍ ដូចជា គាត់មានការលំបាកក្នុងការចុះជណ្តើរជាដើម។

ដារ៉ាក៏ត្រូវរៀនថែទាំខ្លួនរបស់គាត់ និងម្តាយរបស់គាត់ តាំងពីគាត់នៅវ័យក្មេងមកម្ល៉េះ។ ម្តាយរបស់ ដារ៉ា បានប្រាប់អង្គការលីកាដូថា ដារ៉ា បានដឹងអំពីបញ្ហាសុខភាពផ្លូវចិត្ត និងផ្លូវកាយ របស់គាត់ ហើយជានិច្ចជាកាល ដារ៉ា យកចិត្តទុកដាក់ពីគាត់ ហើយរំលឹកគាត់ឲ្យលេបថ្នាំ ទៀតផង។

ដោយសារតែ ដារ៉ា មិនអាចបញ្ចេញអារម្មណ៍ និងភាពភ័យខ្លាចតាមពាក្យសម្តីបាន លទ្ធផលនៃកម្រងសំនួរទាក់ទងនឹងចំណុចខ្លាំង និងការលំបាក (SDQ) ដែលចូលរួមបំពេញ ដោយឪពុកម្តាយ ដារ៉ា យាយ និងយាយតាបង្កើតរបស់ ដារ៉ា ត្រូវបានប្រើប្រាស់ ក្នុងការវាយតម្លៃ អំពីអាកប្បកិរិយាកាលពីអតីតកាល និងពេលបច្ចុប្បន្នរបស់ដារ៉ា។ នៅក្នុងលទ្ធផលនៃកម្រង សំនួរទាក់ទងនឹងចំណុចខ្លាំង និងការលំបាក (SDQ) នេះ អារម្មណ៍មិនសប្បាយចិត្ត និងការ លំបាកក្នុងការផ្តោតអារម្មណ៍ និងការលំបាកផ្នែកកាយវិការរបស់ ដារ៉ា ស្ថិតនៅចន្លោះខ្ពស់ និងខ្ពស់ខ្លាំង ហើយលទ្ធផលនេះបង្ហាញថា គាត់មានការលំបាកក្នុងការចុះសម្រុងជាមួយកុមារដទៃទៀត។ បុគ្គលិកអង្គការអ៊ីនឌីហ្គោ (Indigo) បានសន្និដ្ឋានថា នេះជាប្រហែលជាដោយសារគាត់មិនធ្លាប់មានកុមារដទៃទៀតលេងជាមួយគាត់ (វាលែងតែរយៈពេលបីបួនខែចេញ) ក្នុងដំណាក់ដំបូងនៃការធំធាត់របស់គាត់ ហើយដូចច្នេះ គាត់មានឱកាសតិចតួច ក្នុងការរៀនរាប់អាន ជាមួយកុមារដែលមានវ័យប្រហាក់ប្រហែលគាត់។ ទោះបីជាបែបនេះក៏ដោយ អ្នកដែលស្គាល់គាត់និយាយថាដារ៉ាជាកុមារសុភាពនិងចេះជួយយករក្សា នេះបើតាមការសិក្សាវាយតម្លៃ ដែលបញ្ជាក់ដោយលទ្ធផលនៃកម្រងសំនួរទាក់ទងនឹងចំណុចខ្លាំង និងការលំបាក (SDQ)។

## ការសម្លឹងមើលទៅអនាគត

នាពេលបច្ចុប្បន្ននេះ ដារ៉ា រស់នៅកន្លែងមួយប្រកបដោយក្តីស្រលាញ់ និងការយកចិត្តទុកដាក់ ហើយគាត់បានសម្របខ្លួនបានយ៉ាងល្អ ក្នុងការរស់នៅជាមួយយាយតាបង្កើតរបស់ ដារ៉ា។ ដារ៉ាហាក់ដូចជា មានភាពស្និទ្ធស្នាល ជាពិសេស ជាមួយជីតារបស់គាត់ ហើយបាន បង្កើតនូវសម្ព័ន្ធភាពដ៏ស្និទ្ធស្នាលជាមួយសមាជិកផ្សេងៗទៀតនៅក្នុងគ្រួសារនោះ។ ដារ៉ា អាចគ្រប់គ្រងកំហឹងរបស់គាត់បានប្រសើរជាងមុន ហើយស្តាប់និងយល់ពីអ្នកដទៃ។ គាត់មានការអត់ធ្មត់ច្រើនជាងមុន យំតិចជាមុន ហើយពេលខ្លះ ដើរចេញពីបញ្ហា។

បើទោះជាឥឡូវនេះ ដារ៉ា ទទួលបានការថែទាំល្អ គាត់នៅតែមានការលំបាក និង បន្តបញ្ចេញនូវអាកប្បកិរិយាបែបកំហឹង និងបំផ្លាញ ហើយនេះអាចជាលទ្ធផលនៃការរងអំពើហិង្សាលើរាងកាយដែលគាត់បានជួបប្រទះ និងបានឃើញ ពេលដែលគាត់រស់នៅក្នុងពន្ធនាគារក្នុងវ័យកុមារ។ ដារ៉ា រឹតតែ មានសភាពឆេវឆាវ ជាពិសេស ពេលដែលគាត់ឃ្លាន ឬ ទាស់ចិត្តអ្វីមួយ រហូតដល់ពេលខ្លះ ដើររកវត្ថុអ្វីមួយ ដើម្បីយកទៅវាយនរណាម្នាក់។ ទោះជាពេលខ្លះ ដារ៉ា អាចស្វែងរកមធ្យោបាយទំនាក់ទំនងផ្សេងក្រៅពីការទំនាក់ទំនងដោយការមិនអាចនិយាយបានក៏ដោយ ក៏ឃើញថា ការតឹងចិត្តភាគច្រើន គឺដោយសារតែការណ៍ដែលគាត់មិនអាចនិយាយបាននេះតែម្តង។

ចាប់តាំងពីចាកចេញពីពន្ធនាគារមក ដារ៉ា បានរៀនចុះសម្រុងជាមួយកុមារដទៃទៀត រៀនចែករំលែក និងចែកវេនគ្នាលេង។ គាត់ចង់លេងជាមួយកុមារដទៃទៀត រៀនធ្វើតាមទង្វើរបស់ពួកគេ និងលេងជាមួយពួកគេ។ ទោះជាយ៉ាណាក៏ដោយ ពេលខ្លះកុមារដទៃទៀត ធ្វើត្រាប់តាមគាត់ ពេលដែលគាត់ព្យាយាមនិយាយ និងសើចចំអកចំពោះគាត់ ពេលដែលគាត់ព្យាយាម និយាយទៅកាន់ពួកគេ។



ម្តាយ និងកូនតូចនៅក្នុងពន្ធនាគារ ខេត្តសៀមរាប ឆ្នាំ២០១៣

ដារ៉ា បានចាប់ផ្តើមចូលរៀនសាលារដ្ឋ ក្នុងខែតុលា ឆ្នាំ២០១៤ ហើយនៅខណៈដែលយាយតាខាងឪពុករបស់ ដារ៉ា ជឿជាក់ថា ដារ៉ា នឹងអាចសម្របខ្លួនបាន បុគ្គលិកអង្គការ ការីតាស កម្ពុជា បានលើកឡើងថា ដារ៉ា ទំនងជាមានការលំបាកក្នុងការរៀនសូត្រ ហើយមានអត្រាខ្ពស់ដែលត្រូវកុមារដទៃទៀតធ្វើបាប។ ដើម្បីឲ្យមានការរីកចំរើនទៅបាន ដារ៉ា ត្រូវការជំនួយពិសេសមួយទល់មួយ និងបន្តបន្ទាប់ ប៉ុន្តែជំនួយបែបនេះ ជាទូទៅមិនមាននៅក្នុងសាលារដ្ឋនៅកម្ពុជាទេ។ តាមពិត សាលារៀនដែលផ្តល់ជំនួយពិសេសដល់កុមារ មានតែបី ឬ បួនប៉ុណ្ណោះ ហើយសាលាដែលស្ថិតនៅជិតបំផុត គឺនៅរាជធានីភ្នំពេញ ដែលត្រូវចំណាយពេលធ្វើដំណើររយៈពេល ៣ ម៉ោង ពីផ្ទះរបស់ ដារ៉ា បច្ចុប្បន្ន។ ទោះជាយ៉ាង ណាក៏ដោយ យ៉ាងហោចណាស់សាលារៀនបច្ចុប្បន្នរបស់ដារ៉ាផ្តល់ឱកាសឲ្យគាត់ក្នុងការទំនាក់ទំនងជាមួយកុមារដទៃទៀត រៀនសូត្រពីអ្នកទាំងនោះ និងបង្កើនជំនាញសង្គម រួមទាំងជំនាញទំនាក់ទំនងផងដែរ។

ដារ៉ា មិនមានលក្ខណៈគ្រប់គ្រាន់ក្នុងការធ្វើសុភវិនិច្ឆ័យ និងបទពិសោធន៍នៃការប្រាស្រ័យទាក់ទងជាមួយ កុមារដ៏ទៃទៀតទេ។ បើទោះជាសមត្ថភាពទាក់ទងនឹងចលនា (Motor Skills) ដូចជាការសរសេរជាដើមរបស់ ដារ៉ា មានភាពប្រសើរជាងមុន ដារ៉ា នៅតែជួបប្រទះនូវការលំបាកជាមួយ នឹងសមត្ថភាពទូទៅទាក់ទង នឹងចលនាទូទៅ (Gross Motor Skills) ដូចជាការរត់ ជិះកង់ ហែលទឹក ជាដើមរបស់គាត់ដដែល ហើយត្រូវការជំនួយពីមនុស្សពេញវ័យជា មួយនឹងកិច្ចការធម្មតា។ ដារ៉ា មានលទ្ធភាពអាចស្នើសុំជំនួយពីគេ ដោយប្រើកាយវិការរបស់គាត់ ហើយជាទូទៅ អនុញ្ញាតឲ្យអ្នកដ៏ទៃជួយគាត់ ដែលនេះអាចបញ្ជាក់បានថា ដារ៉ា កំពុងតែសម្របខ្លួនរបស់គាត់ ទៅនឹងតួនាទី ដែលសមនឹងអាយុរបស់គាត់បច្ចុប្បន្ន និងស្ថានភាពដែលគាត់កំពុងរស់នៅនៅក្នុងបរិបទគ្រួសារធម្មតាមួយ។



កុមារ និងម្តាយនៅក្នុងពន្ធនាគារ ខេត្តប៉ៃលិន ឆ្នាំ២០១១

អ្នកផ្ត ល់ការព្យាបាលតាមបែបវេជ្ជសាស្ត្រ (Therapist) របស់ ដារ៉ា បានផ្តល់លំហាត់សម្រាប់អនុវត្តការនិយាយ ដល់ ដារ៉ា ជាទៀងទាត់ ដើម្បីឲ្យគាត់យកទៅអនុវត្តវានៅផ្ទះ ប៉ុន្តែយាយតារបស់ ដារ៉ា មិនបានអនុវត្តវាមួយ ដារ៉ា ទេ។ បុគ្គលិកអង្គការការីតាស (Ca tiras-CCAH) ជឿថានេះ ប្រហែលជាដោយសារពួកគាត់ខ្វះនូវទំ នុកចិត្តក្នុងការអនុវត្តវា ឬ ក៏ពួកគាត់មិនយល់ អំពីតម្លៃនៃលំហាត់សម្រាប់អនុវត្តការនិយាយនេះ ចំពោះសមត្ថភាពនិយាយរបស់ ដារ៉ា នាពេលខាងមុខ។

នៅពេលដែល ដារ៉ា ចាកចេញពីពន្ធនាគារលើកដំបូង ដារ៉ា បានស្រក់ទឹកភ្នែកយ៉ាងច្រើនហើយគាត់មើលទៅនៅតែក្រៀមក្រំពេលដែលគាត់ត្រូវឃ្លាតឆ្ងាយពីសមាជិកគ្រួសារដែលជិតស្និទ្ធនឹង គាត់ ឬ អ្វីៗដែលនៅជុំវិញគាត់។ ដារ៉ា ហាក់ដូចជានៅតែមិនមានទំនាក់ទំនងល្អជាមួយម្តាយរបស់គាត់ ដែលបញ្ហានេះត្រូវបានឃើញ ពេលដែលគាត់ទៅសួរសុខទុក្ខម្តាយគាត់នៅពន្ធនាគារ។ អំឡុងពេលដំបូងនៃការសួរសុខទុក្ខម្តាយនៅពន្ធនាគារ ដារ៉ា មានសភាពមិនសប្បាយចិត្ត ហើយមិនឲ្យម្តាយរបស់គាត់ប៉ះ ឬ កាន់គាត់នោះទេ។ នេះប្រហែលជាដោយសារឥទ្ធិពលនៃអំពើរំលោភបំពាន ដែលម្តាយរបស់ ដារ៉ា បានប្រព្រឹត្តលើ ដារ៉ា កាលពីមុន។ បុគ្គលិក អង្គការអ៊ីនឌីហ្គោ (Indigo) បានសង្កេតឃើញថា ដារ៉ា មិនសប្បាយចិត្តភ្លាមៗ យំយ៉ាងខ្លាំង ហើយធ្វើខ្លួនរឹងយ៉ាងខ្លាំង ពេលដែលម្តាយរបស់គាត់លើក និងអោបគាត់។ ទំនាក់ទំនងរវាង ម្តាយ និងកូនគាត់ បានចាប់ផ្តើមមានភាពប្រសើរជាមុនបន្តិចបន្តួច ប៉ុន្តែ ដារ៉ា នៅតែស្ទាក់ស្ទើរ ក្នុងការឲ្យម្តាយអោបគាត់ដដែល។

ផ្ទុយទៅវិញ ជានិច្ចជាកាល ដារ៉ា ហាក់ដូចជាសប្បាយចិត្តក្នុងការជួបជាមួយ "យាយ" របស់គាត់ដែលជាប់ពន្ធនាគារ ហើយគាត់មានសភាពធម្មតាពេលដែលយាយគាត់ប៉ះ ឬ លើក ពគាត់។ តាមពិតទៅឃើញថា គាត់មានទំនាក់ទំនងខ្លាំងជាមួយ ដារ៉ា ពេលនៅក្នុងពន្ធនាគារ ហើយបើទោះជាអត្តចរិតរបស់គាត់គួរឲ្យចោទសួរក៏ដោយ គាត់ប្រហែលជាអាចបានផ្តល់ឲ្យ ដារ៉ា នូវស្នេហភាពខ្លះៗពេលនៅក្នុងពន្ធនាគារ។ អំឡុងពេលតាមដានលើដារ៉ាពេលដែលគាត់ទៅជួបសួរសុខទុក្ខឪពុករបស់គាត់ បើទោះ ដារ៉ា ដំបូងមិនស្គាល់ឪពុក ហើយពេលខ្លះ មិនចង់មករកឪពុក របស់ខ្លួនក៏ដោយ ប៉ុន្តែឃើញថា ឪពុករបស់ ដារ៉ា ស្លូតបូត ហើយមានក្តីស្រលាញ់ចំពោះ ដារ៉ា ហើយគាត់មានអារម្មណ៍មិនសប្បាយចិត្តយ៉ាងពិតប្រាកដ ពេលដែលកូនរបស់គាត់មិនស្គាល់គាត់។ ដារ៉ា ហាក់ដូចជាខ្លាចមន្ត្រីពន្ធនាគារ ប៉ុន្តែគាត់ហាក់ដូចជាយល់ថា គាត់គ្រាន់តែមកទីនោះ ដើម្បីមកសួរសុខទុក្ខម្តាយរបស់គាត់ប៉ុណ្ណោះ ហើយគាត់ នឹងមិនស្ថិតនៅទីនោះទេ។

បើទោះជា ដារ៉ា មិនមានភស្តុតាងផ្នែកវិជ្ជសាស្ត្រ ដែលបញ្ជាក់អំពីកម្រិតខ្ពស់នៃជម្ងឺថប់បារម្ភ ភ័យខ្លាច ឬ ប៉ះទង្គិចផ្លូវចិត្ត ការបន្តភ័យខ្លាចរបស់ ដារ៉ា ជាមួយនឹងអ្វីថ្មីៗ និងមនុស្សប្លែកមុខ អាចប៉ះពាល់ដល់ការលូតលាស់របស់គាត់ ដោយរារាំងគាត់មិនឲ្យសាកល្បងអ្វីថ្មីៗ ហើយ ដូចច្នេះ ធ្វើឲ្យឱកាសរៀនសូត្រសម្រាប់គាត់នៅមានកម្រិត។ទោះជាយ៉ាងណានៅពេលដែលគាត់សម្របខ្លួនបានល្អជាងមុន ជាមួយនឹងកន្លែងរស់នៅថ្មី និងការយកចិត្តទុកដាក់ថែទាំពីក្រុមគ្រួសារ ហើយគាត់មានទំនាក់ទំនងកាន់តែជិតស្និទ្ធ ការតាំងចិត្តក្នុងការប្រថុយប្រថាន និងការសាកល្បងនូវអ្វីថ្មីៗ ទំនងជាមានការកើនឡើង។

ចាប់តាំងពីកូនប្រុសរបស់គាត់ត្រូវបានចាប់ខ្លួន យាយតាខាងឪពុកបង្កើតរបស់ ដារ៉ា បានជួបប្រទះ បញ្ហាថវិកា។ ពួកគាត់បានលក់ដី ដើម្បីបង់ថ្លៃសេវាមេធាវី ហើយចំណាយផ្សេងទៀតពាក់ព័ន្ធនឹងការទៅមកពន្ធនាគារ។ ឥឡូវពួកគាត់ជួបការលំបាកក្នុងការផ្គត់ផ្គង់ម្ហូបអាហារឲ្យបានគ្រប់ គ្រាន់សម្រាប់សមាជិកគ្រួសារគាត់ទាំងអស់គ្នា។ អង្គការមិនមែនរដ្ឋាភិបាលមួយ បានជួយឧបត្ថម្ភពួកគាត់នូវអង្ករចំនួន ២៥ គីឡូក្រាម ក្នុងមួយខែ ហើយនឹងថ្លៃធ្វើដំណើរទៅ មកកន្លែងព្យាបាលតាមបែបមិនមែនវេជ្ជសាស្ត្រនៅទីក្រុងតាខ្មៅ ដែលត្រូវចំណាយពេលវេលាធ្វើដំណើរ ចំនួន ៣ ម៉ោង ពីគេហដ្ឋានរបស់គាត់។

# សេចក្តីសង្ខេប

ដោយសារម្តាយ ដារ៉ា បានបន្តប្រើថ្នាំញៀន ក្នុងពេលមានផ្ទៃពោះ ទំនងជាមានបញ្ហាខ្លះ ទាក់ទងនឹងបញ្ហាវិញ្ញាណ ឬ ការចងចាំ ហើយប្រហែលជា បញ្ហាទាក់ទងនឹងការនិយាយរបស់គាត់ បានចាប់មានបញ្ហាពេលនៅក្នុងស្បូន។ គេដឹងជាទូទៅថា ទារក ដែលបានប្រឈមនឹងថ្នាំញៀន ក្នុងពេលមានផ្ទៃពោះ ប្រឈមនឹងបញ្ហាទាក់ទងនឹងការលូតលាស់នៃសសៃប្រសាទ ហើយការសិក្សាស្រាវជ្រាវខ្លះ បានលើកឡើងអំពីឥទ្ធិពល នៃការប្រើប្រាស់ថ្នាំញៀនរបស់ម្តាយដែលប៉ះពាល់ចំពោះការលូតលាស់ផ្នែកការនិយាយស្តីរបស់កូន។[១៣]

ប៉ុន្តែក៏ច្បាស់ផងដែរថា បញ្ហាទាក់ទងនឹងការលូតលាស់របស់ ដារ៉ា ក៏ជាលទ្ធផលនៃការរស់នៅក្នុងពន្ធនាគាររបស់គាត់ផងដែរ។ បើទោះជាគាត់មិនបានបង្ហាញរោគសញ្ញាជាក់ច្បាស់ នៃបញ្ហាប៉ះទង្គិចផ្លូវចិត្ត ដូចជា សុបិន្តមិនល្អ ការភ័យព្រួយខុសពីធម្មតា ឬ ការបាត់បង់ការរីករាយ ឬ ការចាប់អារម្មណ៍ កាលដែលគាត់ស្នាក់នៅក្នុងពន្ធនាគារ និងការវាយដំដែលគាត់បានជួបប្រទះ ក្នុងនាមជាកុមារក្មេងម្នាក់ ទំនងជាមានផលប៉ះពាល់ទៅលើបញ្ហាវិញ្ញាណ ឬ ការចងចាំការលូតលាស់និងកម្រិតនៃសប្បាយភ្ញាក់ផ្អើលនិងការភ័យព្រួយ។ ដោយសារតែបានកាត់ផ្តាច់ពីសង្គម ខាងក្រៅ ការមិនយកចិត្តទុកដាក់ និងការរំលោភបំពានពីសំណាក់ម្តាយរបស់ខ្លួន និងអ្នកដ៏ទៃ ដារ៉ា ត្រូវបានដកហូតនូវឱកាសក្នុងការកសាងសម្ព័ន្ធភាពដ៏ជិតស្និទ្ធ និងកក់ក្តៅជាមួយក្រុមគ្រួសាររបស់គាត់។ ផ្ទុយទៅវិញ ដារ៉ា ហាក់ដូចជាបានកើតនូវ អារម្មណ៍មិនជឿជាក់ទៅលើម្តាយរបស់គាត់ និងពិភពលោកជុំវិញគាត់។

ដារ៉ា ពិតជាទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដោយសារបទពិសោធន៍ និងការលំបាកក្នុងពន្ធនាគារ បរិយាកាសរស់នៅដ៏អាប់អួរ និងកង្វះអាហារូបត្ថម្ភគ្រប់គ្រាន់ និងការថែទាំសុខភាពឲ្យបានត្រឹមត្រូវ ការជម្រុញលើកទឹកចិត្តសមស្របសម្រាប់កុមារ និងការទំនាក់ទំនងជាមួយកុមារដ៏ទៃទៀត។ បើទោះជាមិនមានភាពច្បាស់លាស់ថា តើបញ្ហាទាក់ទងនឹងការលូតលាស់ របស់គាត់កម្រិតណា បានកើតឡើងនៅក្នុងស្បូន និងកម្រិតណាកើតឡើងដោយសារលទ្ធផល នៃការរស់នៅក្នុងពន្ធនាគារក៏ដោយ ក៏ការមិនយកចិត្តទុកដាក់ដែល ដារ៉ា បានជួបប្រទះជាច្រើន ត្រូវគេដឹងថា មានផលប៉ះពាល់ទៅនឹងបញ្ហាទាក់ទងនឹងការលូតលាស់ និងការយឺតយ៉ាវនៃការនិយាយស្តី និង ស្តាប់ភាសារបស់គាត់។

ជាទូទៅ អង្គការលីកាដូ គាំទ្រចំពោះកិច្ចខិតខំប្រឹងប្រែងក្នុងការធានាថា ទារកដែលទើប នឹងកើត និងកុមារតូចៗ មានឱកាសបន្តរស់នៅជាមួយម្តាយដែលជាប់នៅក្នុងពន្ធនាគារកម្ពុជា។ អង្គការលីកាដូ ទទួលស្គាល់នូវអត្ថប្រយោជន៍នៃការអនុញ្ញាតឲ្យកុមាររស់នៅជាមួយម្តាយ រហូត ដល់ពួកគាត់អាយុ ៣ ឆ្នាំ ក្នុងលក្ខខណ្ឌដែលពន្ធនាគារអាចផ្តល់នូវបរិយាកាសប្រកបដោយ សុវត្ថិភាព សុខភាពល្អ និងបរិយាកាសសមស្របសម្រាប់កុមារ។ ក្នុងចំណោមកត្តាជាច្រើនកត្តានេះ អាចជួយកាត់បន្ថយនូវការបោះបង់កុមារចោលដែលអាចកើតមាន ឬ បញ្ជូនកុមារឲ្យទៅ រស់នៅកន្លែងដែលមិនល្អគ្រប់គ្រាន់ ហើយផ្តល់ឲ្យកុមារនូវការចិញ្ចឹមថែទាំ ដោយមានទំនាក់ទំនងរវាងម្តាយ និងកូន។

ទោះជាយ៉ាងណា អង្គការលីកាដូ ជឿជាក់ថា កុមារគួរស្នាក់នៅក្នុងពន្ធនាគារបានទាល់ តែមានការសិក្សាវាយតម្លៃ ដែលធ្វើការពិចារណាទៅលើកត្តាពាក់ព័ន្ធទាំងអស់ រួមទាំង អត្ថប្រយោជន៍ និងហានិភ័យផងដែរ។ ត្រូវតែមានការតាមដានមើលបន្តចំពោះកុមារទាំងនេះ ហើយវិធានការការពារជាពិសេសត្រូវតែមានជាស្រេច ដើម្បីបំពេញសេចក្តីត្រូវការរបស់ម្តាយ និងកូន។ ទាល់តែបំពេញនូវចំណុចទាំងអស់នេះ ទើបសមស្រប និងសមហេតុផល ក្នុងការអនុញ្ញាតឲ្យកុមារបន្តស្នាក់នៅក្នុងពន្ធនាគារ។

ចំពោះករណីរបស់ ដារ៉ា មិនមានការសិក្សាវាយតម្លៃការតាមដាន និងវិធានការការពារ បែបនេះឡើយ។ គាត់បន្តរស់នៅក្នុងពន្ធនាគារជាមួយម្តាយ ដោយមិនបានគិត ឬ ពិចារណាទៅលើវិធានការណ៍ផ្សេងៗទៀតនោះទេ។ បើទោះជាពីដំបូង ឃើញថាហាក់ដូចជាចាំបាច់ និងសមស្របចំពោះ ដារ៉ា ក្នុងការស្នាក់នៅជាមួយម្តាយក្នុងពន្ធនាគារ ដើម្បីកសាងសម្ព័ន្ធភាព និងការបំបៅដោះក៏ដោយ ក៏ប៉ុន្តែពេលមានការរំលោភបំពានកើតឡើង ហើយមានបញ្ហាទាក់ទងនឹងការលូតលាស់របស់គាត់ យើងឃើញកាន់តែច្បាស់ គួរតែប្រាកដជាក់ច្បាស់ថាមានវិធានការចំបាច់ត្រូវធ្វើឡើង ដើម្បីធានាថា ដារ៉ា ត្រូវបានដកហូតពីពន្ធនាគារក្នុងលក្ខណៈសមស្រប និងទាន់ពេលវេលា។

ប្រសិនបើមានការសិក្សាវាយតម្លៃឲ្យបានត្រឹមត្រូវ តាំងពីដំបូង ប្រហែលជាបានដឹងច្បាស់ថា ការរស់នៅជាមួយយាយតារបស់គាត់ជាជម្រើសមួយដ៏សមស្រប ហើយ ដារ៉ា ក៏បានរួចផុតពីការរំលោភបំពាន ក្តីហ្មងសៅ និងការមិនទទួលបានអ្វីផ្សេងៗ ដោយសារតែការរស់នៅក្នុងពន្ធនាគារផងដែរ។ បើទោះជា ដារ៉ា ប្រហែលជាខ្វះឱកាសក្នុងការកសាងសម្ព័ន្ធភាពរវាងម្តាយ និង កូន ប៉ុន្តែគាត់ប្រហែលអាចយកឈ្នះ លើបញ្ហាពាក់ព័ន្ធនឹងការលូតលាស់របស់គាត់មួយចំនួន។ តាមពិត បុគ្គលិកអង្គការការីតាស (Caritas-CCAMH) បានផ្តល់មតិយោបល់ថា ប្រសិនបើ ដារ៉ា បានចាក ចេញពីពន្ធនាគារកាលពីអាយុ ១ ឆ្នាំ ហើយបានទទួលការជួយសមស្របនាពេលនោះ ប្រហែលឥឡូវ គាត់អាចនិយាយទំនាក់ទំនងបានប្រសើរជាងមុន អាចជៀសផុត ពីបញ្ហាទាក់ទងនឹងអាកប្បកិរិយារបស់គាត់ជាច្រើន និងសមត្ថភាពទូទៅទាក់ទងនឹងចលនា (Gross Motor Skills) ផងដែរ។

អាជ្ញាធរកម្ពុជាត្រូវតែទទួលស្គាល់នូវផលប៉ះពាល់ដែលអាចកើតមានមួយចំនួន ទៅលើកុមារទាំងអស់ ដោយសារការរស់នៅក្នុងពន្ធនាគារ ហើយចាត់វិធានការ ដើម្បីដោះស្រាយហានិភ័យផ្សេងៗ ដោយការពិនិត្យឡើងវិញអំពីការសម្រេចចិត្តនានា។ អាជ្ញាធរត្រូវតែយកចិត្តទុកដាក់ផងដែរ ចំពោះស្ថានភាពជាក់ស្តែងរបស់កុមារម្នាក់ៗ

[១៣] សូមមើល http://aia.berkeley.edu/media/pdf/shah_children_meth.pdf

ហើយផ្តល់ការបណ្តុះបណ្តាលបុគ្គលិក ដើម្បីពួកគាត់អាចដឹង ពេលមានបញ្ហាកើតឡើង ហើយអាចឆ្លើយតប ឬ ដោះស្រាយ បានសមស្រប។

ចំពោះករណី ដារ៉ា ហាក់មិនឃើញថា ឱកាសក្នុងការកសាងសម្ព័ន្ធភាពជាមួយម្តាយរបស់គេ មានលើសលុប ចំពោះបទពិសោធន៍អវិជ្ជមានដោយសារការរស់នៅក្នុងពន្ធនាគារនោះទេ។ ផ្ទុយទៅវិញ ដារ៉ា បានចំណាយពេលវេលារបស់គាត់ នៅកន្លែងដែលមានហិង្សា ហើយ ការសិក្សាអប់រំ និងសុខភាពរបស់គាត់មិនមានការអើពើ ហើយបញ្ហាពាក់ព័ន្ធនឹងការលូតលាស់ របស់គាត់ក៏មិនត្រូវបានគេយកចិត្តទុកដាក់ផងដែរ។ ប្រសិនបើមិនមានបញ្ញត្តិនៅក្នុងច្បាប់ពន្ធនាគារឆ្នាំ២០១១ នោះទេ ដារ៉ាប្រហែលបន្តស្ថិតនៅក្នុងពន្ធនាគាររហូតដល់អាយុ ៦ ឆ្នាំហើយមើលទៅ។

ដូចនឹងករណីសិក្សាលើកមុនរបស់អង្គការលីកាដូ សាច់រឿងរបស់ ដារ៉ា បង្ហាញឲ្យឃើញ ពីសារៈសំខាន់យ៉ាងខ្លាំងនៃការមានជាស្រេចនូវវិធានការពិសេស ពេលដែលកុមារត្រូវបានដាក់ ឲ្យនៅជាមួយម្តាយនៅក្នុងពន្ធនាគារ។ ប៉ុន្តែសាច់រឿងរបស់ ដារ៉ា ក៏បង្ហាញពីភាពធ្វេសប្រហែសរបស់អគ្គនាយកដ្ឋានពន្ធនាគារ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងការសិក្សា វាយតម្លៃឲ្យបានត្រឹមត្រូវ ដើម្បីសម្រេចថាតើ កុមារគួរតែស្នាក់នៅក្នុងពន្ធនាគារតាំងពីដំបូង ឬក៏ ចាត់វិធានការ ប្រសិនបើកុមារប្រឈមនឹងហានិភ័យផ្សេងៗ។

ចំពោះដារ៉ា អនាគតរបស់គាត់មិនដឹងទៅជាយ៉ាងណានោះទេ។ ចាប់តាំងពីចាកចេញពី ពន្ធនាគារមក សមត្ថភាពធ្វើចលនារាងកាយរបស់គាត់មានភាពប្រសើរជាងមុនបន្តិច ហើយ បុគ្គលិកអង្គការការីតាស (Caritas-CCAM) ជឿជាក់ថា រាងកាយរបស់គាត់នឹងកាន់តែប្រសើរឡើង ប៉ុន្តែនឹងមិនបានដូចកុមារដ៏ទៃទៀតនោះទេ។ គាត់ទំនងជាមិនអាចនិយាយបានដូចគេ ធម្មតា ហើយដូចច្នេះ គាត់នឹងបន្តជួបប្រទះបញ្ហានៅឯសាលារៀន និងពេលដែលគាត់ពេញវ័យ។



ជនជាប់ឃុំជាម្តាយ និងកូនប្រុស នៅក្នុងពន្ធនាគារ ឆ្នាំ២០១៣

## អនុសាសន៍

### ►►► ការសិក្សាវាយតម្លៃលើស្ថានភាពបុគ្គលឲ្យបាន គ្រប់ជ្រុងជ្រោយ (***)

អគ្គនាយកដ្ឋានពន្ធនាគារ រួមជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គួរតែធ្វើការសិក្សាវាយតម្លៃអំពីស្ថានភាពរបស់កុមារម្នាក់ៗ ដើម្បីសម្រេចថា ជម្រើសណាមួយ ជាជម្រើសប្រសើរជាង ប្រសិនបើដាក់កុមារឲ្យនៅដាច់ដោយឡែកពីម្តាយដែលជាប់ពន្ធនាគារ ឬ ថាតើកុមារគួររស់នៅជាមួយម្តាយរបស់គេក្នុងពន្ធនាគារ។ ការវាយតម្លៃនេះ គួរតែត្រូវធ្វើឡើង (ព្រោះវាជាបទដ្ឋានសម្រាប់ប្រទេសជាច្រើននៅលើពិភពលោក) មុនពេល កុមារចូលទៅរស់ នៅក្នុងពន្ធនាគារ។ ការវាយតម្លៃដូចគ្នានេះ ក៏ត្រូវតែធ្វើឡើងផងដែរ នៅពេលដែលកុមារ ចាប់កំណើតក្នុងអំឡុងពេលម្តាយកំពុងជាប់ឃុំឃាំង ដើម្បីសម្រេច ថាតើកុមារគួរស្នាក់នៅក្នុង ពន្ធនាគាររយៈពេលយូរប៉ុណ្ណា ឬ មិនគួរស្នាក់នៅស្នាក់នៅទាល់តែសោះតែម្តង។ ការវាយតម្លៃនេះ គួរប្រកាន់យកវិធីសាស្ត្រពេញលេញ ដោយពិនិត្យទៅលើឧត្តមប្រយោជន៍ និងសិទ្ធិរបស់កុមារក្នុងការលូតលាស់ ព្រមទាំងផលប្រយោជន៍ពីការបន្តទំនាក់ទំនងរវាងម្តាយ និងកូនប្រសិនបើ កុមារនោះស្នាក់នៅជាមួយម្តាយក្នុងពន្ធនាគារ។ ការវាយតម្លៃនេះ គួរតែពិចារណាផងដែរ ទៅលើប្រព័ន្ធសុខុមាលភាពរបស់កុមារកម្ពុជា ដែលមិនទាន់អភិវឌ្ឍន៍គ្រប់គ្រាន់ ហើយនិង ហានិភ័យនៃការបោះបង់ចោលកុមារ និងដាក់នៅមណ្ឌលស្នាក់ដែលមិនល្អគ្រប់គ្រាន់។

### ►►► ការគ្រប់គ្រង និងការតាមដានមើលបន្ត

ការសិក្សាវាយតម្លៃលើករណីនីមួយៗ ត្រូវតែធ្វើឡើងជាបន្តបន្ទាប់ ដោយសារការប្រែ ប្រួលស្ថានភាពនៅក្នុងពន្ធនាគារ និងការកើនឡើងនៃតម្រូវការរបស់កុមារ។ ការសិក្សាវាយតម្លៃ គួរតែធ្វើឡើង ដោយមានពេលវេលាកំណត់ច្បាស់លាស់ ហើយពិចារណាទៅលើភាពលូតលាស់ចាស់ទុំ សុខភាព ទំនាក់ទំនងជាមួយម្តាយ និងជម្រើសសមស្របផ្សេងៗជំនួសឲ្យការរស់នៅក្នុង ពន្ធនាគារក៏ដូចជាឥទ្ធិពលនៃការរស់នៅក្នុងពន្ធនាគារដែលមានជាបន្តបន្ទាប់ ចំពោះសុខភាព និងការលូតលាស់របស់កុមារ។

### ►►► ការការពារកុមារ

អគ្គនាយកដ្ឋានពន្ធនាគារ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គួរតែ ធ្វើការស៊ើបអង្កេត ចាត់វិធានការ និងការកត់ត្រា នូវរាល់ការចោទប្រកាន់នានា ទាក់ទងនឹងការ រំលោភបំពានចំពោះកុមារក្នុងពន្ធនាគារ។ ប្រសិនបើស្ថាប័នទាំងពីរទទួលបានព័ត៌មានអំពីស្ថានភាពដែលកុមារប្រឈមនឹងគ្រោះថ្នាក់ ស្ថាប័នទាំងនោះត្រូវតែចាត់វិធានការជាបន្ទាន់ ដើម្បីការពារកុមារ។ ពន្ធនាគារត្រូវតែថែរក្សាឯកសារទាំងអស់ ទាក់ទងនឹងសុខភាពរបស់កុមារដែលរស់នៅជាមួយម្តាយក្នុងពន្ធនាគារ ហើយធ្វើការចែករំលែកព័ត៌មានទាំងនេះជាមួយអ្នកមានវិជ្ជាជីវៈផ្នែកវេជ្ជសាស្ត្រដទៃទៀត ទៅតាមភាពសមស្រប។

### ►►► គោលការណ៍ណែនាំពិស្តារ (***)

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដោយមានការសហការជាមួយ អគ្គនាយកដ្ឋានពន្ធនាគារ គួរតែចេញសេចក្តីណែនាំទាំងឡាយ ស្តីពីរបៀបអនុវត្ត និងពង្រឹងប្រព័ន្ធផ្ទេរទៅខាងក្រៅ (បញ្ជូន) និងការដាក់កុមារអាយុលើសពី ៣ ឆ្នាំឡើងទៅដែលកំពុង រស់នៅក្នុងពន្ធនាគារ ឲ្យស្ថិតនៅក្រោមអាណាព្យាបាលរបស់បុគ្គល/ស្ថាប័នណាមួយខាងក្រៅ ពន្ធនាគារ។ នេះជាការចាំបាច់ដើម្បីធានាថា ការបំបែកកុមារពីម្តាយត្រូវតែបានគ្រប់គ្រង និងអនុវត្តទៅដោយមានភាពសមស្រប និងមានពេលវេលាច្បាស់លាស់ ហើយតែក្នុងករណី ដែលមានការរៀបចំទទួលយកកុមារមកចិញ្ចឹមថែទាំខាងក្រៅមានរួចជាស្រេច។ គោលនយោបាយដែលមានស្រាប់តាំងពី ខែមេសា ឆ្នាំ២០០៦ ស្តីពីការថែទាំជំនួសសម្រាប់កុមារនៅប្រទេសកម្ពុជា បានផ្តល់ក្របខណ្ឌមួយយ៉ាងល្អដែលចែងថា ជម្រើសទី១ គឺត្រូវដាក់កុមារឲ្យ ស្ថិតក្រោមអាណាព្យាបាលរបស់សាច់ញាតិ បន្ទាប់មកការថែរក្សារបស់ឪពុកម្តាយចិញ្ចឹម ហើយបន្ទាប់មកទៀត ដាក់ក្នុងមណ្ឌលកុមារ។

### ►►► ការដោះលែងបណ្តោះអាសន្នក្រោមការត្រួតពិនិត្យ និងទោសមិនឃុំខ្លួន (***)

ស្របតាមវិធានទីក្រុងបាងកក អាជ្ញាធរតុលាការគួរតែកំណត់ស្វែងរកនារីដែលមានកូន ក្នុងបន្ទុក (នៅក្នុង ឬនៅក្រៅពន្ធនាគារ) ដែលជាបេក្ខជនសម្រាប់ការដោះលែងបណ្តោះអាសន្ន ក្រោមការត្រួតពិនិត្យ និង/ឬទោសមិនឃុំខ្លួន។ អាជ្ញាធរគួរតែធ្វើការតស៊ូមតិជាមួយចៅក្រម និងព្រះរាជអាជ្ញា ដើម្បីរក្សាភាពជួបជុំរបស់ក្រុមគ្រួសារ ក្នុងករណីដែលអាចធ្វើបាន ដើម្បីកុំបង្ខំ ឲ្យកុមារត្រូវទៅរស់នៅក្នុងពន្ធនាគារជាមួយម្តាយរបស់គេ ឬក៏ទុកពួកគេចោលនៅខាងក្រៅ ឡើយ។ អាជ្ញាធរគួរ តែផ្តោតការយកចិត្តទុកដាក់ផងដែរ ចំពោះនារី ដែលត្រូវបានបញ្ជូន មកពន្ធនាគារស្របពេលគាត់មានផ្ទៃពោះ។ ការដោះលែងបណ្តោះអាសន្នក្រោមការត្រួតពិនិត្យ និង/ឬទោសមិនឃុំខ្លួនសម្រាប់នារីមានផ្ទៃពោះ អាចកាត់បន្ថយចំនួនកុមារ រស់នៅជាមួយម្តាយ របស់ពួកគេក្នុងពន្ធនាគារផងដែរ។

### ►►► ការបណ្តុះបណ្តាល និងកម្មវិធីលើកម្ពស់ការយល់ដឹង (***)

បុគ្គលិកពន្ធនាគារគួរតែទទួលការបណ្តុះបណ្តាល ស្តីពីការលូតលាស់របស់កុមារ ហើយ និងសេចក្តីត្រូវការផ្នែកការថែទាំសុខភាពរបស់កុមារ និងនារីមានផ្ទៃពោះ ដើម្បីឲ្យពួកគេអាច ឆ្លើយតបសមស្របនៅពេលត្រូវការ និងនៅពេលមានភាពអាសន្ន។ គួរតែចាត់ឲ្យមានអ្នកឯកទេសដើម្បីតាមដានពីការចម្រើនលូតលាស់របស់កុមារ ដើម្បីអាចដឹងតាំងពីណាក់កាលដំបូង ប្រសិនបើមានបញ្ហាអ្វីកើតមានឡើង។

►►► ការបន្ថែមធនធាន (***)

អគ្គនាយកដ្ឋានពន្ធនាគារ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គួរតែផ្តល់ធនធានបន្ថែមទៀត ដើម្បីស្វែងយល់បានប្រសើរជាងមុន និងលើកស្ទួយសិទ្ធិកុមារ និង នារីជាម្តាយក្នុងពន្ធនាគារ ដើម្បីពិនិត្យឡើងវិញនូវដំណើរការនៃការធ្វើសេចក្តីសម្រេច ដែលនាំឲ្យកុមារតាមម្តាយរបស់គេទៅរស់នៅពន្ធនាគារ និងវាយតម្លៃផលប៉ះពាល់ពីការឃុំខ្លួនដែលមាន ចំពោះកុមារ។

►►► ការចែករំលែកព័ត៌មាន និងការណែនាំ (***)

អគ្គនាយកដ្ឋានពន្ធនាគារ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួង សុខាភិបាល និងក្រសួងយុត្តិធម៌ គួរតែបង្កើន និងសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីចែករំលែកព័ត៌មាន និងណែនាំមន្ត្រីទាំងឡាយ អំពីសេចក្តីត្រូវការរបស់នារីមានផ្ទៃពោះ និងកុមាររស់នៅជាមួយម្តាយរបស់ពួកគេក្នុងពន្ធនាគារកម្ពុជា។

►►► ការបង្កើនថវិកា

អគ្គនាយកដ្ឋានពន្ធនាគារគួរតែបង្កើនថវិកា និងធនធានផ្សេងៗ សម្រាប់នារីមានផ្ទៃពោះ និងនារីដែលត្រូវបំបៅដោះកូន ព្រមទាំងកុមារដែលរស់នៅជាមួយម្តាយរបស់ពួកគេក្នុង ពន្ធនាគារ។ នេះរួមទាំងការបង្កើនថវិកាសម្រាប់របបអាហារជនជាប់ឃុំប្រចាំថ្ងៃផងដែរ។

(***) អនុសាសន៍ជាច្រើន ស្រដៀងគ្នាទៅនឹងអនុសាសន៍ដែលត្រូវបានស្នើនៅក្នុងរបាយការណ៍អង្គការ លីកាដូ កាលពីលើកមុន "កុមារភាពនៅក្នុងពន្ធនាគារៈការចម្រើនវ័យនៅក្នុងពន្ធនាគារកម្ពុជាៈ រឿងរ៉ាវរបស់សុគន្ធ" ខែតុលា ឆ្នាំ២០១៣ ដែលមិនទាន់ត្រូវបានអនុវត្តឲ្យបានពេញលេញ។